«កូនស្រីផ្ទះប៉ែនពេជ្រ»

«ទុកពេលឲ្យខ្ញុំខ្លះសិនទៅ! នេះជាអ្វីដែលខ្ញុំចង់សុំចិត្ត!»

នាងទច់ដំណើរនៅមាត់ទ្វារហើយដកដង្ហើមយូរបន្លប់ភាពរំញោចញាប់នៃបេះដូង។ នាងឈ្មោះពៅបញ្ញាកូនស្រីពៅនៃគ្រួសារប៉ែនពេជ្រ។
ជាលើកដំបូងបង្អស់ក្នុងមួយជីវិតជាកូនស្រីរបស់អភិជនដែលនាងបានឮពាក្យអង្វរ ប៉ែនពេជ្រ ។

មនុស្សក្នុងត្រកូលនេះមិនធ្លាប់សូម្បីតែនិយាយវែងអន្លាយ ទៅកាន់អ្នកណាម្នាក់តាមទូរស័ព្ទកុំថាឡើយដល់ទៅសុំ អង្វរគេថ្នាក់នេះ។ លើកនេះតរុណីដឹងថា លោកឪពុកប្រាកដជាប្រឈមនឹងកាលៈទេសៈដ៏លំបាកបំផុតហើយ។
នាងឈានជើងចូលទៅយឺតៗ ព្រោះនាងស្ដាប់មិនបានទេថាអ្នកម្ខាងណោះកំពុងឆ្លើយតបចំពោះការអង្វរកនេះដោយរបៀបណា ប៉ុន្តែនាងមានអារម្មណ៍ថាអាកប្បកិរិយាមនុស្សដែលលោកឪពុក ខ្លួនកំពុងសុំក្ដីមេត្តានោះ គឺអវិជ្ជមានច្រើនជាង។

«ខ្ញុំពិតជាមិនទាន់មានមធ្យោបាយមែនក្ហយយុត្តនា!»
កល្យាណីក្តុកក្នុងចិត្ត និមិត្តតែឮអ្នកមានគុណបន្លឺពីឈ្មោះបុរសនោះនៅចុងបំផុត នៃឃ្លាដ៏អស់សង្ឃឹម។ ត្របកភ្នែកអមលំអដោយរោមងរដូចបក្សីមយូរាទម្លាក់សម្លឹង កម្រាលឈើដែលឃើញតែស្រមោលប្រអប់ជើងញ័រចំប្រប់របស់ខ្លួន។ នាងប្រាប់ខ្លួនឯងថា ក្នុងដំណាក់កាលនេះ នាងមិនអាចទន់ខ្សោយហើយមិនអាចដួលឡើយ។
មេធាវីស្រស់ចំណាប់ ឈានយឺតៗទៅហើយលើកដៃព្រហើនរំលងចិត្តបិតាដោយចុចប្រអប់បញ្ចេញសូរសំឡេងនៃទូរស័ព្ទដើម្បីបានស្ដាប់ថា បុរសនៅខ្សែម្ខាងដែលកំពុងគ្រប់គ្រងស្ថានការណ៍បានក្នុងការ ធ្វើបាបចិត្តអ្នកមានគុណនាង គេកំពុងវាចាយ៉ាងណាតបទៅនឹងការអង្វរកររបស់លោក។
ស្នូរពីចុងម្ខាងស្ងាត់ច្រៀប ប្រៀបបាននឹងវិនាទីនៃការគាបសង្កត់ទឹកចិត្តអភិជនឪពុកនិងកូនឲ្យ ធ្លាក់ក្នុងសភាពតឹងតែងស្ទើរផុត ដង្ហើម។ នាងមិនចង់ទ្រាំតទៅទៀតឡើយក្នុងពេលអ្នកនៅម្ខាងនោះសំងំស្ងៀមមិន និយាយ។

មេធាវីស្រីរបស់យើងត្រៀមថាហាសួរទៅគេទៅហើយ ស្រាប់តែសំឡេងបុរសនោះលាន់មកមួយៗតែច្បាស់ៗ៖
«លោកឧកញ៉ា! បើអ្នកណាៗឮមិនផ្ទាល់ត្រចៀក គេជឿអត់ ថាលោកដល់វេនងាកមករកពឹងខ្ញុំ?»
ធីតាយើងស្ទើរផុតដង្ហើមដួលនៅពេលឮពាក្យស៊កសៀតរបស់នាយ។ នាងមិនដឹងថាតើមុននេះ គឺមុនពេលដែលនាងបើកប្រអប់សំឡេងស្តាប់ បុរសនេះបានប្រើវាចាឌឺដងកម្រិតណាមកកាន់បិតាខ្លួននោះទេ។
នាងដឹងហើយថាគេមានរឿងអីអត់ឱនឲ្យគ្រួសារនេះ?។
ចិត្តគេយ៉ាងណា គំនិតគេយ៉ាងណា មិនចាំបាច់ប្រាប់ក៏ដឹងថាគេរកឱកាសបំផ្លាញត្រកូលនេះជាយូរមក ហើយ។ ពេលនេះលោកឪពុកសុខចិត្តពោលពាក្យសុំផ្លូវមួយពីគេ ក៏ដោយសារលោកពិតជាទ័លច្រកមែន។
មិនទាន់ចម្លើយ ថាយ៉ាងណាផងសំឡេងបុរសពីចុងម្ខាងពោលមកបន្ថែម៖
«បានតើ! យោគយល់ថាលោកដាក់ខ្លួនដល់ថ្នាក់មកសុំជំនួយពីមនុស្សដែលលោកដឹង ហើយថាមិនងាយស្រួលក្នុងការជួយលោកទេ បើអញ្ចឹងក៏មានន័យថាលោកឧកញ៉ាត្រៀមរួចរាល់ក្នុងការទទួលយក លក្ខខណ្ឌរបស់ខ្ញុំដែរ?»ទំនងជាភាពសោះអង្គើយនៃបុរសក្មេងជាង ធ្វើឲ្យអភិជន ប៉ែន ពេជ្រ អស់ទឹកចិត្តក្នុងការសុំការយោគយល់ទើបលោកពោលសួរដោយធុញថប់៖
«និយាយមក ចង់យ៉ាងម៉េច?»
ធីតាឈានទៅកាន់ដៃលោកពុកថ្នមហាក់ ចង់បញ្ជាក់ថាកុំឲ្យលោកខឹងសម្បារនាំតែប៉ះពាល់ដល់សុខភាព ល្មមពេលសំឡេងសោះ អង្គើយនៃបុរសនោះលាន់ឡើងមួយៗស្រាលៗតែច្បាស់ៗ៖
«បញ្ជូន ពៅបញ្ញា មក!»
គេនិយាយល្មមៗ សំឡេងនោះមិនធ្ងន់មិនស្រាលតែក៏អាចឲ្យ ពៅបញ្ញា មេធាវីយើងព្រឺខ្នង។ បេះដូងនាងលោតញាប់ក្នុងពេលនាងចាប់អារម្មណ៍ថា កដៃបិតាក៏ញ័ររំជួយដោយសារផ្ទុះកំហឹង។ឧកញ៉ា ប៉ែន ពេជ្រ ស្រែកទាំងញ័រមាត់ទទ្រើក៖
«ចង្រៃយក្ស! ឯងនិយាយស្អី?»
នារីអភិជនស្លេកស្លាំងបបូរមាត់តែនាងខំទប់ចិត្តមិនឲ្យកញ្ជ្រោលទៅ ភាពហ្មងសៅ។ នាងដឹង

ហើយថាបុរសនោះចង់បានអ្វីប៉ុន្តែសំណួរផ្ទួនរបស់បិតាធ្វើ ឲ្យគេនោះហាមកបញ្ចប់ក្ដី
ស្រពេចស្រពិលរបស់នាង៖
«លុយជំពាក់ច្រើនយ៉ាងនេះ លោកឧកញ៉ាឲ្យកូនស្រីចេញដេកក្រៅផ្ទះតែប៉ុន្មានយប់មានអី
ខាតទៅ? ខ្ញុំទុកផ្លូវរស់មួយឲ្យលោកនោះអី! លោកគួរអរគុណខ្ញុំមិនមែន?»

បិតាចំណាស់សឹងថាគ្រវែងឧបករណ៍បញ្ជូនសំឡេងទៅតាមកំហឹងចិត្ត និងវោហារដែល
បញ្ចេញមកតាមភាពពុះកញ្ជ្រោលនៃចិត្តតែលោកប្រឹង អត់ធ្មត់និយាយគ្នាឲ្យចប់។
«បិទមាត់ភ្លាម! បើមិនអញ្ចឹងយើងនឹងប្រដៅឯង»
បុរសចំណាស់បោះទូរស័ព្ទទៅលើលំហដើម្បីសម្រួលកំសួលភ្លើងកំហឹងក្នុង ពេលការប្រមាថ
កាតទានលើកិត្តិយសកូនស្រីបានធ្វើឲ្យបេះដូងលោកលោត កញ្ជ្រោល។
សូរឧបករណ៍ឌីជីថលប៉ះទៅនឹងជញ្ជាំងរបូតបញ្ច្រាសលោតតុកៗលើកម្រាល ព្រំ ឯរាងកាយ
អភិជន ប៉ែន ពេជ្រ ក៏ទោរទន់រកបាត់ជំហរធ្វើឲ្យកូនស្រីភ័យរន្ធត់ស្ទុះទៅត្រកង។
មាត់នាងស្រែករកជំនួយដោយរន្ធត់ផង៖
«ជួយផងៗ»
ក្រុមអ្នកបម្រើដែលចច្រប់នៅខាងក្រៅបន្ទប់ធ្វើការ ព្រោះការបារម្ភនោះបានរត់ស្រចូលមក
ដើម្បីជួយថៅហ្វាយធំ។ ពួកគេគ្រាលោកឧកញ៉ាដែលកំពុងរងវិបត្តិហិរញ្ញវត្ថុមិនធ្លាប់មាន ក្នុង
ជីវិតទៅកាន់បន្ទប់សម្រាក ខ្លះរត់ទៅហៅវេជ្ជបណ្ឌិតប្រចាំគ្រួសារក្រោមបរិយាកាសថប់សឹង
គ្មាន ខ្យល់ដកដង្ហើមរបស់ស្ត្រីជាកូនទោល។
នាងនឹកឃើញដល់២៤ម៉ោងមុននេះគឺពេលដែលនាងនៅសហរដ្ឋអាមេរិកនៅឡើយ អ្នកមាន
គុណបានទូរស័ព្ទហៅនាងត្រលប់ចោលបេសកកម្មការងារកណ្ដាល ផ្លូវ។
នាងដឹងថា លោកមុខតែជួបហេតុការណ៍ដ៏អាក្រក់ដែលនាងមិនដែលប្រឈមមុខឡើយ។ តែ
នាងមិននឹកស្មានថា ហេតុការណ៍អាក្រក់នោះ គឺអកុសលរហូតដល់អ្នកមានគុណត្រូវបង្ខំចិត្ត
ចំពើបនឹងសត្រូវចាស់ហើយ លោកដាច់ចិត្តនិយាយសុំក្ដីមេត្តាពីគេ តែគេបានសងមកវិញញ
នូវវាចាប្រមាថគ្រោតគ្រាត ហើយចុងក្រោយបានវាយផ្ដួលជំហរលោកដោយលក្ខខណ្ឌដ៏
អាស្រូវគឺឲ្យនាង ទៅជួបគេ។
ស្រីម្នាក់ត្រូវទៅជួបប្រុសម្នាក់តើមានអ្វីក្រៅតែពីការប្រមាថជាន់ពន្លិចកិត្តិយសគ្រួសារ ប៉ែន
ពេជ្រ ទៅ?

នាងដកដង្ហើមយូរតាមទម្លាប់ដែលប្រើសម្រាប់បន្ធូរខ្លួនឯងពីចំណង បញ្ហារបស់មេធាវីនានា។ នារីអ្នកច្បាប់វ័យក្មេងដៀងភ្នែកមករកវេជ្ជបណ្ឌិតដែលកំពុងចាក់ ថ្នាំជូនលោកឪពុក។ នាងរង់ចាំទាំងតឹងទ្រូងទម្រាំបុរសចំណាស់នោះបញ្ចប់ការងាររបស់គាត់ ហើយងាកមកប្រាប់នាង៖
«ឧកញ៉ាគ្រាន់តែធ្លាក់តង់ស្យុងខ្សោយប៉ុណ្ណោះ ខ្ញុំចាក់ថ្នាំជូនលោកសម្រាកហើយ! គ្រាន់តែខំបំប៉នអាហារ និងសម្រាកឲ្យបានច្រើន ស្ថានភាពលោកនឹងប្រសើរវិញ! អ្នកនាងកុំបារម្ភពេក»
នារីធូរចិត្តខ្យាក។សុខភាពបិតានៅតែជារឿងចម្បងពេលនេះ។
ពេលគំនាបទីមួយបានរើរួចនាងនិយាយទាំងញញឹមជាកិច្ចគួរសម៖
«អរគុណលោកពូពេទ្យណាស់!»
លោកវេជ្ជបណ្ឌិតរាដៃឃាត់សេចក្ដីគួរសម នោះព្រោះលោកដឹងថាធីតាកំពុងនៅសល់គំនាបបញ្ហាជាច្រើនជំពូកទៀត។
លោកវាចាមុនពេលចាកចេញ៖
«ស្អែកពូមកទៀតអ្នកនាងគិតពីសុខភាពខ្លួនផង!»
ធីតាញញឹមឱនកាយសំពះគាត់ហើយឲ្យសញ្ញាអ្នកបម្រើស្ត្រីវ័យចំណាស់ ឲ្យជូនដំណើរភ្ញៀវ។ នាងងាកមកសម្លឹងបិតាហើយឱនទៅសម្រួលផាហ៊ុមដណ្ដប់ជូនលោកទាំងទុក្ខ ព្រួយពេញកែវនេត្រាថ្លាមុត។

វត្តមានជំនួយការអ្នកមានគុណទាំងទ្វេដែលនៅឈរលឹបលមាត់ទ្វារបាន បង្ខំឲ្យធីតាត្រូវចាកចោលអ្នកមានគុណក្នុងគ្រាដ៏កម្សត់នេះជា ចាំបាច់។ នាងងើបមុខសម្លឹងទៅអ្នកបម្រើចំណាស់ម្នាក់ទៀតដែលកំពុងរលីងរលោង៖
«មីងទុំ! មីងថៃរក្សាលោកប៉ាផង! មីងកុំឃុំឲ្យលោកឃើញណ៎ា! អត់អីទេ! ខ្ញុំនឹងទុកដាក់អ្វីៗទាំងអស់ឲ្យរៀបរយ! មីងឈប់ព្រួយទៅ»
អ្នកបម្រើខំញញឹមលួងចិត្តកល្យាណីក្នុងពេលនាងនាំកាយចាកចេញទៅ។ មកដល់មាត់ទ្វារនាងមិនហ៊ានសម្លឹងមុខជំនួយការទាំងទ្វេដោយសារមិន ចង់ចំពើបនឹងភាពក្រៀមក្រំក្នុងពន្លឺភ្នែករបស់ពួកគេឡើយ។ ស្រីតូចបន្លឺតិចៗ៖
«តោះបង! ទៅនិយាយគ្នានៅបន្ទប់ធ្វើការខ្ញុំ!»
បុរសជំនិតទាំងទ្វេរបស់ឧកញ៉ា ប៉ែន ពេជ្រ ទាញសម្រួលអាវធំហើយដើរតាមធីតាត្រកូលខ្ពស់។

២

«ល្បែងលុយ១១លាន»

«បងវណ្ណៈ! ខ្ញុំចង់ដឹងរឿងគ្រប់សព្វបែបយ៉ាង»

វណ្ណៈជំនួយការស្រស់សង្ហាដែលខំបិទបាំងភាពខ្វល់ខ្វាយបន្លឹមកកាន់នារីយើងមួយៗ៖
«ទាក់ទងនឹងគម្រោង Prasat City! ដីនោះក្លែងក្លាយ! លោកឧកញ៉ាទិញពី Mr Johan តម្លៃ ១១លានដុល្លារ! ស៊ីញេផ្ទេរលុយម្សិលមិញ ១០នាទីក្រោយមក Mr Johan បាត់ខ្លួន! ដីនោះតាមពិត មានម្ចាស់ផ្សេង!»
មេធាវីពៅបញ្ញាទន់ជើងហើយថយអង្គុយយឺតៗទៅលើកៅអីផ្អែក។

សំឡេងជំនួយការដដែលលាន់មកបន្ត៖
«វានោះមានផែនការបោកប្រាស់ពូកែចំណាប់ណាស់ រហូតដល់យើងចាញ់បោកបានមែន! សំខាន់ពេលនេះ ភាគ ហ៊ុនទាំងអស់យល់ថា លោកឧកញ៉ារួមគំនិតបោកយក លុយនោះ! លោកឧកញ៉ាចាំបាច់ត្រូវមានលុយនោះឲ្យទៅក្រុមហ៊ុនវិញ! គេទុកពេលតែមួយអាទិត្យទេអ្នកនាង!»

នារីរវេភ្នែកសម្លឹងកម្រាលឥដ្ឋពណ៌ក្រហមក្រមៅ។
នាងមានជំនាញខាងច្បាប់ អ្វីៗគឺរឹងគ្មានមនោសញ្ចេតនាទេ ប៉ុន្តែរឿងជំនួញជារឿងផ្សេង។ នាងមិនយល់ហើយក៏គ្មានយោបល់អ្វីឲ្យប្រសើរឡើយ។ ទឹកប្រាក់ច្រើនយ៉ាងនេះ កុំថាឡើយ ៧ថ្ងៃ សូម្បី៧ខែក៏វេទនាដែរសម្រាប់នាង។
«ខ្ញុំនឹងទៅជួបពិភាក្សាជាមួយអ៊ំៗ! គាត់គួរណាស់តែយោគយល់យើង ហើយជួយយើងរកច្រក
ចេញមិនមែនមកជាន់យើងថែមទេ មែនទេបងវណ្ណៈ? បងរិទ្ធិ?»
បុរសសម្បុរស្រអែមស្រស់ឈ្មោះរិទ្ធិ ក្អកគ្រហែមយកសូរសំឡេងបំបាត់ភាពស្ងប់ស្ងាត់ដែលគេរក្សាបានរហូតមក។ គេនិយាយតបធីតាយើង៖
«មិនបាច់ទេអ្នកនាង លោកឧកញ៉ាក៏គេមិនយល់មុខដែរ! មនុស្សទាំងនោះស្គាល់តែ

ប្រយោជន៍ ស្គាល់តែលុយ! ពេលឧកញ៉ាចេញគម្រោង Prasat City អ្នកណាក៏គាំទ្រ ពេលទៅទិញដីពី Johan អ្នកណាក៏មិនជំទាស់ ដល់មានរឿងគេព្រមានថា នឹងប្ដឹងពីបទក្បត់ទំនុកចិត្ត! មនុស្សទាំងអស់នោះពិតជាស្គាល់មុខមាត់ពេលអាសន្នមែន!»

នារីវ័យក្មេងផ្អែកខ្នងទៅនឹងបង្អែកហាក់ល្ហិតល្ហៃ។ សូម្បីមនុស្សធ្លាប់ល្អនឹងគ្នា ក៏បោះបង់គ្នាចោលដែរក្នុងគ្រានេះ? នាងហួសចិត្តហើយធ្មេចភ្នែកដែលក្ដៅគគុកដោយវិបត្តិ។ ស្រីហារមាត់និយាយទាំងមិនបើកភ្នែក៖

«បងរិទ្ធិ! ម៉េចក៏មុននេះខ្ញុំមកទាន់លោកប៉ានិយាយជាមួយម្នាក់.....យុត្តនា នោះ?»

គឺនាងមិនចង់រំលឹកពីឈ្មោះគេទេ។ មនុស្សនេះជាមនុស្សដែលនាងបានខំបំភ្លេចចោលយ៉ាងលំបាក។ ជាប្រភេទមនុស្សគ្មានតម្លៃនិងគ្មានថ្ងៃដែលនាងផ្ដល់ការគោរព ស្រលាញ់សាជាថ្មីឡើយរាប់ចាប់តាំងពីថ្ងៃដែលគេបានជាន់ឈ្លីគ្រួសារ នាង។

ល្ងាចនេះគេបានប្រើសម្ដីប្រមាថគ្រួសារនាង អ្នកមានគុណនាងនៅនឹងមុខនឹងមាត់តាមថានាងមិនព្រមសូម្បីតែអាន ឈ្មោះរបស់គេតែនាងចាំបាច់ត្រូវដឹងថាហេតុអ្វីបានជាលោកប៉ារបស់ នាងសុខចិត្តឱនកាយទៅរកមនុស្សប្រភេទនោះ។

នាងដឹងថាគេគ្មានលុយទេគេមិនមែនជាអភិជនតែជាប្រភេទមនុស្សកាប់ដាវបង្កបញ្ហាច្រើនតាមរយៈចំណេះដឹងតិចតួចរបស់គេ។

សម្ដីជំនួយការរិទ្ធិលាន់មកវិញតបនឹងសំណួរនាង៖

«ព្រោះធនាគារទាំងអស់គ្មានអ្នកណាព្រមជួបលោកឧកញ៉ាទេ! មានតែងាកទៅរកហ្លួតយុត្តនា!»

ធីតាគ្រវីក្បាលតិចៗ នាងបើកភ្នែកព្រឹមសម្លឹងមុខបុរសនោះ៖

«ខាងយើងទាក់ទងទៅគេមុនមែនអត់បង?»

ជំនួយការរូបនោះដឹងថានាងចង់បន្ទោសតែគេនៅតែពោលប្រាប់តាមត្រង់៖

«ខ្ញុំអត្តនោម័តិសុំជួបខាងគេមុន!»

នារីដកដង្ហើមវែង។

«ខ្ញុំសុំទោស! តែខ្ញុំគិតដល់លោកឧកញ៉ា! មួយសប្ដាហ៍ អត់វែងប៉ុន្មានទេ!»

«បងអត់ខុសទេ!» នាងឆ្លើយកំបុតព្រោះមិនចង់ស្ដាប់តទៅទៀត។ «ប៉ុន្តែគេជួយយើងតាមវិធីណា? គេម៉េចនឹងមានលុយច្រើនម្ល៉ឹង?»

«អត់ទេ! តែគេមានបណ្ដាញច្រើន គេថាគេដឹងពីអ្នកដែលបោកប្រាស់យើងនោះ! ថាឥឡូវនៅ

ឯណា! ខ្ញុំនិយាយពី Mr Johan»
តរុណីបើកភ្នែកធំៗព្រោះភ្ញាក់ផ្អើល។ នាងដឹងថាតាមច្បាប់បើអាចរកឃើញជនបោកប្រាស់នោះ ឪពុកខ្លួននឹងលាងកិត្តិយសបាន ហើយអ្វីៗនឹងវិលមកល្អវិញតែមួយប៉ប្រិចភ្នែក។
ជំនួយការដដែលនិយាយតិចៗបន្ថែម៖
«បើយើងចាប់គេនោះបានមែន! មិនត្រឹមលោកឧកញ៉ាគេចរឿងលើកនេះរួចទេ យើងនឹងអាចសួរវានោះដឹងថាអ្នកណានៅពីក្រោយរឿងបោកប្រាស់នេះផង!»
បុរសនោះសួរបន្ថែម៖
«លោកយុត្តនាថាព្រមជួយបើលោកឧកញ៉ាទូរសព្ទទៅផ្ទាល់! ចុះ....មិញនេះការនិយាយគ្នាតាមទូរស័ព្ទយ៉ាងម៉េច?»
ពៅបញ្ញា មិនចង់រំលឹកពីការសន្ទនានោះឡើងវិញទេ ប៉ុន្តែដំណាក់កាលនេះ នាងគ្មានឱកាសលាក់បាំងឡើយព្រោះនៅចំពោះមុខគឺជាមនុស្សដែលជិះទូក ជាមួយគ្នា។ នាងបញ្ចេញភាពក្រៀមក្រំតាមពន្លឺភ្នែកមិនឆ្លើយនឹងសំណួរបែរជា បង្គាប់៖
«បើបងរិទ្ធិជាអ្នកទាក់ទងគេនោះ! បងទាក់ទងទៅសួរគេទៅ! ឲ្យខ្ញុំទៅជួបនៅកន្លែងណា! ស្អែកខ្ញុំទៅជួបគេ!»
វណ្ណៈភ្ញាក់ព្រើតក្នុងពេលនាយរិទ្ធិធ្វើមុខស្មើ។ អ្នកទាំងពីរយល់ពីន័យនេះក្នុងពេលបេះដូងស្រីលោតស្ទើររហែកទ្រូង។

បុត្រីត្រកូលអភិជនដែលមិនដែលសូម្បីតែមានស្នេហាឬសាសងផ្លែផ្កា ទៅកាន់បុរសណាម្នាក់ ថ្ងៃនេះដោយសារគេមានវត្ថុជាទីសង្ឃឹមចុងក្រោយរបស់លោកប៉ានាង ក្នុងដៃ នាងសុខចិត្តជឿតាមជំនួយការទៅរកគេ ទោះបីថាលក្ខខណ្ឌរបស់គេគឺអាចឲ្យនាងទទួលក្តីអាម៉ាស់ពេញក្នុង សង្គមជាន់ខ្ពស់ក៏ដោយ។
សម្តីនាងធ្វើឲ្យជំនួយការទីមួយប្រកែកញ៉ាញ៖
«បើចង់ជួយ ចាំបាច់អីដាក់អាលក្ខខណ្ឌឆ្កួតៗអស់នេះ! អ្នកណាទៅជួប មានអីខុសគ្នា?!»
«គឺវាខុសគ្នាបង! ព្រោះគេចង់ជាន់ឈ្លីខ្ញុំ នៅក្រោមបាតជើងរបស់គេ!»
វណ្ណៈថ្លោះទឹកមុខ នាយនិយាយភ្លាមទាំងមុខស្លេកដោយសារខំប្រឹងទប់កំហឹង៖
«ដឹងអញ្ចឹងហើយអ្នកនាងទៅធ្វើអី?»
នារីនៅស្ងៀមបន្តិច នាងឈ្ងោកមុខហើយនិយាយបន្ត៖

«ព្រោះយើងអត់មានផ្លូវជ្រើសរើសទេ បង!»
រិទ្ធិដែលអត់មាត់មួយម៉ាត់ដកដង្ហើមធំបែរខ្នងចាកចេញទៅ។ សំឡេងនាយវណ្ណៈលាន់មកវិញ៖
«វាចង់យ៉ាងម៉េចវា? គ្រាន់តែជាអ្នកលេងប៉ុណ្ណឹងវាមិនមែនថៅកែធំមានលុយវាល់លានឯណា?»
ពៅបញ្ញារក្សាភាពស្ងប់ស្ងៀមធ្វើឲ្យបរិយាកាសក្នុងបន្ទប់កាន់តែ តានតឹងនិងគួរស្រណោះស្រណោក។ នាងក្រឡេកទៅរករូបថតអ្នកម្ដាយនៅចុងតុធ្វើការ។
«អ្នកម៉ាក់! ទោះកូនជាកូនស្រី តែកូនត្រូវតែរឹងប៉ឹងដូចបណ្ដាំអ្នកម៉ាក់ កូនជាកូនរបស់ប៉ាដែលត្រូវតែគាំទ្រលោកប៉ាឲ្យដល់ទីបំផុត! កូនមិនខ្លាចទេ កូនមិនខ្លាចអ្នកណាទាំងអស់!» នាងនឹកម្នាក់ឯងក្នុងចិត្ត ប៉ុន្តែសំឡេងនាយជំនួយការលាន់មកបន្ត៖
«បើរឿងនេះឮដល់អ្នកក្រៅ....»
នាយវណ្ណៈមិននិយាយបញ្ចប់ទេប៉ុន្តែមាណវីដឹងហើយថា តើគេចង់មានន័យថាម៉េច។ នាងនិយាយមួយៗដោយទប់ចិត្តសង្វេគ៖
«អ្នកណានិយាយមិនសំខាន់ទេ តែលោកប៉ាមិនអាចមានរឿងឡើយ!»
វណ្ណៈនិយាយលែងចេញព្រោះចុងក្រោយ សុវត្ថិភាពរបស់ថៅហ្វាយធំគឺជម្រើសអាទិភាព។ ប្រាក់ច្រើនម្លឹងៗ ពៅបញ្ញា ជាអ្នកច្បាប់ស្រាប់ នាងដឹងហើយថាតើនាងគួរឃើញអ្នកមានគុណដើរចូលពន្ធនាគារឬនាងខ្លួន ឯងត្រូវដើរទៅនរក?
ស្នូរជើងនាយរិទ្ធិវិលមកវិញ។ គេនៅសំចតពីមុខប្រុសស្រីទាំងពីរដោយទឹកមុខស្ងួត ហើយទើបវាចាមួយៗ៖
«គេឲ្យអ្នកនាងទៅពេលនេះ!.....ខ្ញុំចង់និយាយពី....លោកយុត្តនា!»
រិទ្ធិសម្លឹងទៅម្រាមដៃស្រស់ស្រីដែលប្រែទៅជាញ័រទទ្រើកអមជាមួយសំឡេងទោសៈរបស់ជំនួយការម្នាក់ទៀត៖
«ស្អីគេវា??? ម៉ោងប្រាំបីប្រាំបួនយប់ហើយណ៎ា! មោះ ខ្ញុំនិយាយជាមួយអាមនុស្សវិកលសតិនោះម្ដង!»
អាវពណ៌សពីក្នុងឯកសណ្ឋានការិយាល័យរបស់ស្ត្រីវ័យក្មេងរំជួយទៅតាម ចង្វាក់ទ្រូងដែលដង្ហក់ព្រោះស្នូរដង្ហើមញាប់ឡើងៗ។ ចង់មិនចង់នាងគឺកំពុងភិតភ័យនិងតឹងតែងទៅដោយសម្ពាធ។

វណ្ណៈហេតុតែអាណិតនិងឈឺចិត្តជំនួសចៅហ្វាយស្រី ទើបគេស្ទុះស្ទាលើកទូរស័ព្ទមកចុចប្រុងថាបញ្ចេញកំហឹង តែត្រូវរិទ្ធិកញ្ឆក់មកហើយនិយាយឃាត់៖
«បើឯងមិនចេះទប់ចិត្តខ្លះទេ ទៅដេកទៅវណ្ណៈ! ពេលនេះយើងទៅរកគេ យើងត្រូវការជួយលោកឧកញ៉ា មិនមែនពេលមកជជែកតថ្លៃឬជេរប្រមាថគេទេ!»
«តែ....តែ...តែវាហួសហេតុ...វាក្អេងក្អាង...វាមិនចេះគិតមុខមាត់អ្នកណាទេ ឯងឃើញអត់? អ្នកនាងសុំត្រឹមស្នែកក៏វាមិនព្រម?»
ធីតា ពៅបញ្ញា ក្រោកឈរយឺតៗពីកៅអី។ នេះគឺជាកម្លាំងចុងក្រោយដែលនាងមានបន្ទាប់ពីដំណើរឆ្លងទ្វីប វែងឆ្ងាយគ្មានអាហារមួយគ្រាប់និងគ្មានច្រកណាផ្សេងសម្រាប់ចេញ។ នាងទាញកាបូបដៃពីលើតុហើយទម្លាក់វាមកទន្ទឹមនឹងភ្លៅព្រោះគ្មាន កម្លាំងសូម្បីតែយោងវា។
«បងរិទ្ធិ! ហៅពូសាន់ចេញឡាន!»
នាងចាកចេញទៅក្រោមកែវភ្នែកក្រហមដោយកំហឹងរបស់នាយជំនួយការ វណ្ណៈ។
រិទ្ធិដកដង្ហើមធំទះស្មាគេម្តងៗហើយនិយាយ៖
«វណ្ណៈ! យើងគ្មានជម្រើសទេ! ខ្លាចតែ....ខ្លាចតែគេដូរចិត្តវិញ....យើងយ៉ាប់ហើយ»
គេប្រុងទៅ ប៉ុន្តែត្រូវវណ្ណៈទាញកអាវមកវិញ។
រិទ្ធិសម្លឹងទៅវណ្ណៈដែលផ្ទៃមុខគេទាំងមូលប្រែជាពណ៌ក្រហមហើយមាត់និយាយទាំងខាំធ្មេញ៖
«បើអាចង្រៃនោះធ្វើបាបអ្នកនាងពៅ! ខ្ញុំជាអ្នកអូសកវាចូលគុកមុនគេ!»
រិទ្ធិរក្សាទឹកមុខស្មើ គេរុញដៃគូកនទម្លាក់ចេញ គេមិនប្រកាន់ព្រោះដឹងថាដៃគូនេះឆេវឆាវបន្តិចព្រោះតែមាន មនោសញ្ចេតនាពេកប៉ុណ្ណោះ។ គេលេបភាពជូរចត់និយាយស្រាលៗមុនចាកចេញ៖
«តែបើគេមិនមែនអ្នកចូលគុក គឺលោកឧកញ៉ាដែលត្រូវទៅជំនួស! យកល្អ ឯងអត់ធ្មត់ឲ្យបានច្រើនជាងនេះបន្តិចទៅវណ្ណៈ»
និយាយចប់ រិទ្ធិចាកចេញពីបន្ទប់មកតាមពីក្រោយចៅហ្វាយស្រីជាមួយទឹកមុខខ្មៅ រោល។ គេដើរបណ្តើរតាមសម្លឹងដំណើរនាងពីក្រោយ ដែលខូចចិត្តដល់ម៉្លឹងហើយដំណើរស្រីនៅតែមួយៗ ស្មើៗហើយនឹងន។

ការប្រគល់ស្រីម្នាក់ដែលយើងស្រលាញ់សឹងថាជាងជីវិតខ្លួនឯងឲ្យ ទៅប្រឈមនឹងមនុស្សក្មេងក្អាងម្នាក់ក្នុងវេលាថ្មើរណេះ តាមពិតអ្នកដែលឈឺចាប់បំផុតគឺម្នាក់ដែលកំពុងឃាត់គេឯងឲ្យចេះ អត់ធ្មត់នេះហើយ។ កំលោះជំនួយការបោះជំហានបណ្តើរចិត្តគេកញ្ច្រោលជាមួយប្រយោគសម្រាប់ ខ្លួនឯង៖

«យុត្តនា! បើឯងធ្វើបាបអ្នកនាង! ឯងនិងខ្ញុំ មុខតែជួបគ្នា!»

គេបញ្ឈប់ដំណើរព្រោះឮស្នូរជើងវណ្ណៈ ជំនួយការដ៏ឆេវឆាវដែលរត់ទទឹងទទែងចេញមក។ រិទ្ធិបែរក្រោយចងចិញ្ចើម ហើយពោលសួរ៖

«ទៅណា?»

សំណួរសោះកក្រោះរបស់គេធ្វើឲ្យធីតាដែលដើរនៅខាងមុខក៏ទប់ដំណើរ ងាកមកវិញដែរ។ វណ្ណៈមិនឆ្លើយនឹងរិទ្ធិទេ តែគេវាចាហួសទៅរកក្រមុំអភិជនតែម្តង៖

«ខ្ញុំជូនអ្នកនាងទៅ!»

ពៅបញ្ញា សម្លឹងអ្នកទាំងពីរម្តងម្នាក់ដោយក្រសែភ្នែកស្លូតបូត។ នាងញញឹមក្នុងស្ថានភាពដែលស្នាមញញឹមនោះហាក់បង្កប់នូវទុក្ខវេទនា ជាងតំណក់ទឹកភ្នែកទៅទៀត។

«បើបងទាំងពីរស្រលាញ់ខ្ញុំ! ជួយលាក់រឿងនេះពីលោកប៉ានិងអ្នកផ្ទះឯទៀតឲ្យបានទៅ! ខ្ញុំអាចដោះស្រាយម្នាក់ឯងបាន! ទុកចិត្តចុះណ៎ា»

ពន្លឺភ្នែកនាងដែលរេសម្លឹងពួកគេជាចុងក្រោយម្តងម្នាក់ហាក់មាន អត្ថន័យបញ្ជាក់ស្រេចហើយថា ប្រសិនពួកគេនៅតែតាមមកទៀត នាងកាន់តែអៀនខ្មាសចំពោះពួកគេ និងកាន់តែឈឺចាប់ទ្វេតែប៉ុណ្ណោះ។

៣

«មនុស្សពីអតីត»

រថយន្តចាកចេញពីភូមិគ្រឹះហើយបង្ហាញខ្លួនលើមហាវិថីព្រះនរោត្តមក្នុងល្បឿនសន្សឹមៗ ព្រោះមិនដឹងត្រូវទៅណាឲ្យប្រាកដ។

ម្ចាស់ស្រីតូចចាកចេញមកទាំងមិនដឹងថាបុរសនោះនៅឯណា ត្រូវទៅជួបមនុស្សក្មេងក្អាងមនុស្សមិនយល់ចិត្តមនុស្សនោះនៅទីណាឡើយ។

នាងចាកចេញមកយ៉ាងរហ័ស ព្រោះចង់គេចពីភាពទាក់ទាមរបស់បាវព្រាវ គេចពីបរិយាកាសដ៏ធ្ងន់ពាប់ និងព្រោះនាងខឹងចំពោះពាក្យចុងក្រោយបង្អស់ដែលនាយជំនួយការនាំមកប្រាប់ «

គេឲ្យអ្នកនាងទៅពេលនេះ!.....ខ្ញុំចង់និយាយពី....លោកយុត្តនា!»។
នាងបត់ឡានវេវ័ព័ទ្ធតាមរង្វង់វិមានឯករាជ្យក្នុងពេលទឹកភ្នែកស្រក់ ចុះមកតក់ៗ ទោះលើកដៃជូតញាប់យ៉ាងណាក៏មិនស្ងួតងាយឡើយព្រោះអស់ពីស្នាម ចាស់រកកលនឹងរលុប តំណក់ទឹកភ្នែកថ្មីហូរធ្លាក់មកទៀតបន្តគ្នាឥតដាច់រហូតដល់ធីតា យើងលែងមានកម្លាំងចិត្តជូតក៏បណ្តោយឲ្យវាធ្លាក់មកតាមចិត្ត តែម្តង។
«អ្នកម៉ាក់! កូនមិនត្រូវការយំដាច់ខាតក្នុងពេលនេះ លោកប៉ាសម្រាន្តលើគ្រែហើយ ផ្ទះ ប៉ែន ពេជ្រ គឺនៅសល់តែកូនម្នាក់គត់! កូនមិនអាចដួល ហើយក៏មិនអាចឲ្យគ្រប់គ្នាឃើញកូនស្រីរបស់ឧកញ៉ាប៉ែន ពេជ្រ ទន់ជ្រាយដល់ថ្នាក់នេះដែរ! កូនអត់យំទេ! កូនសន្យា!»
សាជាថ្មី ធីតាលើកប្រអប់ដៃឆ្វេងទន់ល្មើយប្រឆាំងនឹងចរាចរណ៍ជលនេត្រ ហើយស្នូរទូរសព្ទបានលាន់មកទាញអារម្មណ៍នាង។
តរុណីពៅបញ្ញាបន្ថយល្បឿនរថយន្ត ហើយលូកដៃក្នុងកាបូបរាវរកទូរសព្ទលើកមកមើល។ វាជាលេខរបស់ជំនួយការដែលនឹងនជាងគេ«Rith»។
ពៅបញ្ញាចុចសារនោះអាន។
«Apartment Campu house #6A»
គេសរសេរមកខ្លីតែនាងយល់ន័យនេះច្បាស់។ វាជាកន្លែងដែលនាងត្រូវទៅក្នុងពេលនេះ។
«ល្ហើយចុះ! មុនក្រោយគង់តែទៅ! ថ្ងៃនេះនិងថ្ងៃស្អែកគ្មានអីខុសគ្នាទេ! ទៅឲ្យហើយ ឲ្យចប់ៗរឿង!»
ក្រោមរាត្រីកាលដ៏ភ្លឺរន្ទាលនៃទីក្រុងគជ់ នាងមេធាវីបត់ឡានបកក្រោយទៅរកសង្កាត់បឹងកេងកងដែលនៅមិនឆ្ងាយ ឡើយពីគេគេហដ្ឋានខ្លួនទើបតែចាកចេញមកមុននេះ។

សង្កាត់បឹងកេងកងដ៏ត្រកាលនៃបណ្តាអភិជនព្រមទាំងជាសង្កាត់ដែល មានជីវភាពដ៏ស៊ីវិល័យសម្រាប់ភ្ញៀវបរទេសនានាបានបង្ហាញផ្លូវទៅរក អាគារ Campu house កម្ពុហោស៍ ខ្ពស់សន្លឹមមិនពិបាករកយូរឡើយ។
តរុណីបញ្ឈរថយន្តកាត់តាមរបាំងសន្តិសុខដែលរត់មកសួរ។ ស្រីរវៃកញ្ចក់ប្រាប់ព័ត៌មាន៖
«ខ្ញុំមានការទៅជាន់ទី៦ ពូ!»
សន្តិសុខឱនក្បាលគោរពមុននឹងវាចាតបមកវិញ៖
«អូ្ហ! ភ្ញៀវលោកយុត្តនា! សូមអញ្ជើញ»

ពៅបញ្ញា ក្តុកក្នុងចិត្តរាល់ពេលឮអ្នកណារំលឹកពីឈ្មោះបុរសនោះ។ នាងឱនមុខលាយស្នាមញញឹមជាមួយពាក្យថាអរគុណហើយបន្តជំនិះទៅរកទី ចំណត។
រថយន្តឈានដល់កន្លែងត្រូវនៅ ឯម្ចាស់វាក៏ដល់កន្លែងដែលត្រូវទៅ ប៉ុន្តែនារីនៅអង្គុយជំអក់ក្នុងឡានដោយបិទភ្នែកទាំងទ្វេហើយដក ដង្ហើមវែងៗ៖
«ពៅបញ្ញា! កុំសាហាវចំពោះខ្លួនឯងពេក ទុកពេលសម្រាប់ខ្លួនឯងប្រាំនាទីសិនក៏មិនអីដែរ!»
នាងនៅបន្តបិទភ្នែករហូតដល់ពាក្យមួយឃ្លាទៀតលាន់មកបន្តក្នុងអារម្មណ៍៖
«មុននិងក្រោយ ពេលនេះនិងពេលបន្តិចទៀត វាដូចតែគ្នាទេ! ចាំបាច់អីបន្ថែមពេលវេលាលំបាកឲ្យខ្លួនឯង?»
នាងក្តាប់មាត់បើកគន្លឹះទ្វារហើយដៃឈោងទាញកាបូបចាកចេញពីក្នុង ឡាន។ រាងកាយស្តមស្តើងសឹងថាមិនទាន់បានឈរនឹងនលើធរណីស្រួលបួលផង សន្ធឹករថយន្តដ៏ព្រហើនបោលមកឆ្វាចហើយបត់វ៉េរមកចតសឹងថាក្បែរ ស្បែកជើងកែងចោតរបស់នាង។ ឡាននោះឈប់ង៉ក់ក្រោមភាពភ័យរន្ធត់របស់ធីតាអ្នកច្បាប់ដែលមិននឹក ស្មានថាលើលោកនេះមានមនុស្សចតឡានគ្មានសុជីវធម៌ដល់ម្លឹង។
នាងងើបមុខសម្លឹងរថយន្តធំជង្គ្រោងពណ៌ខ្មៅស្និលដែលចតទទឹងទទែង បង្ហាញភាពព្រហើនរឹងត្អឹង ប៉ុន្តែទឹកមុខម្ចាស់ឡានដែលបើកទ្វារចេញមកខ្វាច់ ហើយងើបមុខមកសម្លឹងនាងគឺមានភាពព្រហើនឆ្មើងកន្ទ្រើងជាងរបៀបចត ឡានរបស់គេទៅទៀត។
«សួស្តី!»
បុរសនៅចំពោះមុខនេះ គឺជាមនុស្សដែលពៅបញ្ញាខានឃើញគេជាយូរមកហើយ។ ១០ឆ្នាំមកនេះធម្មជាតិក៏គង់ប្រែប្រួល អាចកុំថាឡើយដល់មនុស្ស តែទោះយ៉ាងណាស្នាមខួចតូចតែជ្រៅនៅចុងបង្អស់នៃស្នាមញញឹមរបស់គេ នៅតែអាចធ្វើឲ្យនាងចំណាំគេបាន។
ដង្ហើមស្រស់ស្រីទៅជាដង្ហក់ព្រោះសម្តាធ ប៉ុន្តែនាងខំទប់ស្មារតីព្រោះបុរសនោះមិនត្រឹមតែមានចរិតក្អេង ក្អាង តែគេថែមទាំងរហ័សនោះរហ័សហួស។
គ្រាន់តែឮពាក្យពីរម៉ាត់ពីបបូរមាត់ រាងកាយធំខ្ពស់របស់គេឈានមកនៅពីមុខនាងស្រេចទៅហើយ។
ជាការពិត នាងមិនដែលនៅក្បែរបុរសណាជិតសែនជិតដល់ថ្នាក់នេះឡើយក្នុងនាមជា កូនស្រីរបស់គ្រួសារ ប៉ែន ពេជ្រ។ សំខាន់ម៉ោងថ្មើរណេះទៀត ហើយនៅក្នុងបរិយាកាសបែបនេះទៀត។

នាងខំតោងកាបូបខ្លួនជាប់ទោះដឹងថាបាតដៃបានបញ្ចេញញើស ដោយសារតែចុះចាញ់ពន្លឺភ្នែកព្រមទាំងស្នាមញញឹមរបស់បុរសនោះ។
គេកំពុងសម្លឹងមកនាង ដោយគ្មានក្រែងចិត្ត និងគ្មានយោគយល់ពីចិត្តមនុស្សស្រី។ គោលដៅនៃពន្លឺភ្នែកនាយគឺតម្រង់រកថ្ងាស ច្រមុះបន្ទាប់មកគឺបបូរមាត់ពៅបញ្ញាវាថាគេក៏លាន់មកតិចៗ៖
«អ្នកនាងមេធាវីឆ្មើងគួរសម! មកលេងខ្ញុំហើយ មុខក៏មិនព្រមមើល! ភ្នែកអីក៏កំណាញ់ម៉ឹងៗ អត់ខ្លាចច្រឡំមនុស្ស គេចាប់លើកដាក់ឡានយកទៅបាត់ទេ?»
សំឡេងគេនៅតែពីរោះដូចកាលពី១០ឆ្នាំមុន។

ស្រាក្រហមរបស់មជ្ឈដ្ឋានសង្គមហាក់លោតមិនបានធ្វើឲ្យសូរសព្ទ នោះមានអ្វីប្រែប្រួលឡើយ គ្រាន់តែអត្ថន័យនៃវាចាដែលនាយនិយាយមកនាង វាលែងទន់ភ្លន់ និងស្និទ្ធស្នាលដូចកាលពីមុន។

កាលពី១០ឆ្នាំពេលជួបគ្នាកាលណា គេតែងហៅនាងថា«ពៅ»។ ឥឡូវនេះ វាបានផ្លាស់ប្តូរមកជា«អ្នកនាងមេធាវី»វិញ។ គិតទៅ ចរិតលក្ខណៈរបស់គេផ្លាស់ប្តូរបានច្បាស់លាស់មែន។ នាងងើបមុខសម្លឹងគេយឺតៗ។ នេះជាក្រសែភ្នែកដែលធ្វើឲ្យស្នាមញញឹមលើបបូរមាត់បុរសនោះផ្លាស់ទៅ ជាស្មើហើយផ្ទៃមុខគេទាំងមូលប្រែទៅជាក្រហម។ គេញញឹមចុងមាត់សាជាថ្មីរំលេចបង្អួតស្នាមខួចរបស់ខ្លួន ប៉ុន្តែក៏ជាស្នាមញញឹមស្ងួតដែលគ្រប់គ្នាគេទុកសម្រាប់ប្រើចំពោះ មនុស្សដែលគេស្អប់តែប៉ុណ្ណោះ។
«នាងក៏មានថ្ងៃនេះដែរពៅបញ្ញា» គេគិតក្នុងចិត្តទន្ទឹមនឹងភាពក្រអឺតក្រអោងផុសចេញតាមពន្លឺភ្នែក។
ប្រហែលភាពក្រៀមស្រពោនលើផ្ទៃមុខនារីធ្វើឲ្យបុរសកាន់តែបានចិត្ត ហើយក៏ប្រហែលជាទុក្ខព្រួយរបស់នាងជាអ្វីដែលត្រេកត្រអាល។ គេសម្លឹងតបនាងវិញដោយគ្មានក្រែងរអែង ជាសញ្ញាថា នាងមានអីមកស៊ូជាមួយខ្លួន?។

ធីតាត្រកូលអភិជន ដកខ្សែភ្នែកមកវិញ។ នាងខំធ្វើមាំទាំនិងសោះអង្គើយ បន្លប់ភាពភ័យព្រួយហើយនិយាយដោយមិនងើបមុខសម្លឹងគេតទៅទៀតឡើយ៖
«ខ្ញុំសុំថាទៅរកភោជនីយដ្ឋានណាមួយក្បែរៗ អង្គុយជជែកគ្នាវិញបានទេ? »
នរៈដឹងហើយថានាងមិនចង់ឡើងទៅជាន់ខាងលើទេ ពិសេសគឺនាងធ្វើមុខស្មើដូចជួបគ្នាលើ

សវនាការ ។
នរៈយុត្តនាគិតក្នុងចិត្តទាំងគ្នាន់ក្នាញ់៖ «សូម្បីប្រើសម្ដីទន់ភ្លន់ឲ្យសមជាមនុស្សស្រីអីបន្តិចក៏អត់? គ្មានដឹងថាខ្លួនឯងមករកគេឲ្យជួយឬអីសោះ ស្មានថាខ្លួននៅក្នុងផ្ទះធំ ជាអ្នកនាងធំទៀតហើយមើលទៅ?»
កាន់តែគិតគឺកាន់តែគ្នាន់ក្នាញ់ក្នុងចិត្តណាស់ តែគេក៏មិនអាចធ្វើអ្វីបានក្រៅពីញញឹមឌឺដង៖ «ដឹងតើ! ផ្ទះខ្ញុំវាមិនឡូយដូចផ្ទះឧកញ៉ា ប៉ែន ពេជ្រ ទេ! តែក៏មិនអត់កាហ្វេញ៉ាំដែរ! ធ្វើកុំភ័យមើល៍!»
គេដើរហួសពីមុខនាងទៅ។ សម្ដីនេះមិនបាច់ពន្យល់ទេគឺបញ្ជាក់ស្រេចហើយថា នាងគ្មានផ្លូវតថ្លៃឡើយ។
បើនាងចង់រកគេ គឺត្រូវដើរត្រុកៗទៅតាមគេ មេធាវីពៅបញ្ញា។
ស្រីតូចសៅហ្មងក្នុងចិត្ត នាងនៅដំអក់រហូតដល់បុរសទៅដល់ជណ្ដើរមុន។ ទីបំផុតទោះដំអក់យូរប៉ុណ្ណាក៏គង់ត្រូវតែបោះជំហានទៅតាមពីក្រោយ គេឃើតៗដដែលជាដដែល។

ស្នូរស្បែកជើងកែងនៃស្ត្រីដែលគ្មានស្នាមញញឹមឈានមកតាមពី ក្រោយនរៈឮសូរតិចៗតែសិចស៊ី។យុត្តនា ញញឹមតិចៗទាំងបែរខ្នងដាក់ស្រី។
«នាងស្មានថាផែនដីនេះវិលផ្ទៀងទៅខាងពួកនាងជានិច្ច ពៅបញ្ញា?»
គេគិតទាំងទោសៈប៉ុន្តែគេមិននិយាយវាចេញមកឡើយទុកឲ្យនារីតូចឈាន ចូលមកក្នុងជណ្ដើរយន្តតាមពីក្រោយនាយដូចកូនតូចដើរតាមម្ដាយ។
បុរសនេះចោលក្លិនក្រអូបនៃប្រសិទ្ធភាពម៉ាកទឹកអប់ដ៏ទាក់ទាញភេទ ផ្ទុយ ដែលគេឃើញនិយមប្រើតែក្នុងចំណោមបុរសដែលមានជីវភាពដ៏ស៊ីវិល័យ ប៉ុណ្ណោះ។ ចំណែកស្រីដ៏ស្រគត់ស្រគំដែលនៅចំពោះមុខគេគឺមិនមានសូម្បីម្សៅ ក្រែមមួយចំណិតលើវង់ភក្ត្រ។
គេឈរពីក្រោយពៅបញ្ញាដោយផ្ដោតភ្នែកទៅរកសំលៀកបំពាក់ការិយាល័យពណ៌ ស្រគាំរបស់នាង និងកញ្ចឹងកលឿងខ្ចីពីក្រោមសំណុំសក់ដែលបួងផុតទៅលើបង្ហាញថា ស្រីម្នាក់នេះមិនបានយកចិត្តទុកដាក់ក្នុងការតុបតែងខ្លួនឲ្យ គ្រាន់បើមុនពេលចេញមកជួបនាយសោះឡើយ។
ក្នុងពេលដែលជណ្ដើរយោងយូរអើយយូរសម្រាប់ពៅបញ្ញា នរៈយុត្តនាដែលនៅពីក្រោយមិនបានបណ្ដោយឲ្យភាពតឹងតែងរបស់នាងរំលង ទៅគ្រាន់តែជាក្ដីស្រមៃទេ គេដើរចូលមកកាន់

តែកៀករហូតដល់តែខ្យល់ដង្ហើមនាយលាន់សន្ធឹកក្បែរ សោតានាង។
នារីរគ្រាប់ភ្នែកព្រោះទើសទាល់ តែនាងក៏មិនស្មានដល់ដែរថា មួយប៉ប្រិចភ្នែកសោះ បុរសនោះលើកម្រាមទាំងសងមកក្រសោបស្មាខ្លួន។
តរុណីបើកភ្នែកធំៗ នាងឈានទៅមុខគេចចេញតែគេនៅតែចូលមកបន្តទោះដឹងថានាងទ័លគ្មានផ្លូវទៅមុខទៀតក្តី។
«គោរពខ្លួនឯងខ្លះផងទៅ!»
នាងនិយាយទាំងសៅហ្មង។ តែយុត្តនាមិនត្រឹមមិនតបតគេថែមទាំងទម្លាក់ដៃមករកចង្កេះនាង ហើយតោងជាប់ម៉ឹងជាងមុនមិនព្រមឲ្យនាងគេចចេញបានតែម្តង។
ពៅបញ្ញានិយាយទាំងខឹងញ័រមាត់៖
«លោកចេះខ្មាសអត់! កាមេរ៉ានៅទីនេះអ្នកយាមគេមើលឃើញណា៎»
«ល្អតើ! នៅខាងលើអត់មានកាមេរ៉ាទេ!»
គេដកដៃចេញវិញ ហើយតែសម្តីឌឺដងរបស់គេធ្វើឲ្យស្ត្រីអ្នកច្បាប់ចាប់ផ្តើមក្តៅ ចិត្តជំនួសភាពភិតភ័យ។ ជាមួយមនុស្សដែលគ្មានសីលធម៌និងគ្មានការគោរពសូម្បីស្ត្រីភេទ ទន់ខ្សោយនាងយល់ថាគួរស្អប់ខ្ពើមគេឲ្យបានច្រើន វាប្រសើរជាងមកឈរខ្លាចញញើតគេ។
នាងបែរក្រោយមកប្រឈមនឹងគេហើយងើបសម្លឹងចំភ្នែកបុរសរូបនេះ។ ទឹកមុខនាងសោះអង្គើយស្របទៅនឹងសម្តីដែលគ្មានទឹកដមមនោសញ្ចេតនា៖
«បើលោកគិតថា មនុស្សស្រីគ្រប់គ្នាទុកសម្រាប់ឲ្យមនុស្សប្រុសមើលងាយ មិនដឹងជាលោកខំរៀនមកឲ្យអស់តែប៊ិចសៀវភៅបានប្រយោជន៍អីទេ?»
កែវភ្នែកនាងមុតពេក ធ្វើឲ្យបុរសទៅជាភ័ន្តភាំង ប៉ុន្តែកំហឹងបែរជាដុតកម្តៅទឹកមុខគ្មានម្សៅក្រែមរបស់នាងឲ្យ អណ្តែតចេញ នូវសម្បត្តិធម្មជាតិដែលបិទបាំងក្រោមចរិតលក្ខណៈនឹងនហួសវ័យ។

គេគគ្រឹតនឹងសម្តីច្រែតៗនោះ ក៏បូញមាត់ផ្លុំបង្ហើរសក់លើថ្ងាសនាងលេង ធ្វើហីឲ្យសក់ស្រីប៉ើងរប៉ាត់រប៉ាយ។ ពៅបញ្ញា កាន់តែសៅហ្មងនឹងចរិតលក្ខណៈដ៏យ៉ាប់នេះ នាងច្រានគេមួយទំហឹង តែបើយុត្តនាទុកខ្លួនឲ្យទ្រេតទ្រោតនោះវាចប់បាត់ទៅហើយ។ បុរសមិនថយបែរជាកាន់តែចូលមកកៀកទាល់តែស្រីស្អាតសាជាថ្មីថយទៅ ទ័លនឹងជ្រុងជណ្តើរហើយស្រែកយ៉ៃព្រោះច្រមុះនាយលោមកក្បែរថ្ពាល់យកតែមែនទែនទៅហើយ។

«ស្តាប់! ពៅបញ្ញា! ស្រីចរិតប្រុស! ខ្ញុំអត់អ្នករៀនអ្នកសូត្រអីច្រើនដូចនាងទេ! ក៏មិនចាំបាច់យកទ្រឹស្តីសីលធម៌កូនប្រុសទ្រូងប្រាំហត្ថអីមក សូត្រដូចគ្នា! ព្រោះខ្ញុំអត់ចេះខ្វល់ផង! បើខ្ញុំចង់ធ្វើអីគឺធ្វើហ្នឹងហើយចាំទុកអ្នកនាងមេធាវី!»

គេខ្សឹបតិចៗក្បែរត្រចៀកនាង។ ទោះគេមិនស្រែកតែពន្លឺភ្នែកគេនិងទឹកមុខគេគឺឌឺដងគ្មានភាពទន់ ជ្រាយនិងស្នាមញញឹមឡើយ។ ទ្វាររបើកខ្លាកជួយបំបាត់ចោលបរិយាកាសដ៏តូចចង្អៀតនេះ ហើយស្នាមញញឹមយុវកំលោះផុសមកវិញបញ្ចេញស្នាមខួចជ្រៅនៅចុងបបូរមាត់ឆ្វេង។

«ដល់ហើយ!»

គេកៀកចង្កេះនាងចូលទៅ ធ្វើឲ្យធីតាប្រឹងបម្រះចេញទាំងក្តៅចិត្ត៖

«ចេះដើរខ្លួនឯងហើយ!»

ដែលខឹងណែនទ្រូងគឺគេដៃដល់អត់ខ្មាស និយាយច្រើនដូចមនុស្សស្រី សម្តីគ្មានក្បាលកន្ទុយគ្មានហេតុផល ហើយពាក្យដែលគួរឲ្យក្តៅចិត្តបំផុតគឺពាក្យថា«ស្រីចរិតប្រុសហ្នឹង ហើយ»។ យុត្តនា ដឹងថានាងខឹង គេក៏កាន់តែសប្បាយចិត្ត។ នាយសើចខឹកចំអកធីតាអភិជន រួចបោះជំហានចូលទៅមុននាង ទុកឲ្យពៅបញ្ញាឈរទ្រឹងនៅមាត់ទ្វារ។

បន្ទប់នោះងងឹតស្លុប ប៉ុន្តែធំទូលាយពេលដែលភ្លើងត្រូវបានចុចបើកដោយដៃម្ចាស់ប្រុសដែលច្រឡើសបើស កាយវិការគ្មានសណ្តាប់ធ្នាប់ ហើយសម្តីគ្មានការយោគយល់។

«អត់ស្អាតដូចវិមានអ្នកនាងមេធាវីទេ! អធ្យាស្រ័យផង!»

ទោះបីយ៉ាងណា សារជាតិមនុស្សប្រុសនៅតែជាមនុស្សប្រុស។ Apartmentនេះស្អាតភ្លឹងតែក៏នៅសេសសល់ក្លិនខ្លួនបុរសដែលប្រឆាំង គ្នានឹងក្លិនទឹកអប់របស់គេ។ មិនមែនជាក្លិនអាក្រក់តែក៏ជាអ្វីម្យ៉ាងដែលស្រីក្រមុំមិនដែលទទួល អារម្មណ៍របៀបនេះពីមុនមកឡើយ។ នាងចាប់អារម្មណ៍ថាគគ្រិច ហើយទើសទាល់។

«ចង់ធ្វើស្ទិលឲ្យខាងប្រុសបីដាក់គ្រែទៀត?»

គេបែរមកនិយាយដោយដើរបកមកវិញយឺតៗព្រោះខាងស្រីឈរទ្រឹងនៅមាត់ ទ្វារមិនដឹងជានាងភ័យឬនាងខឹងនឹងសម្តីគ្មានយោគយល់នេះឬយ៉ាង ណាទេ។ មកដល់ជិតទើបគេដឹងថាភ្លើងកំហឹងជះចេញពីពន្លឺភ្នែកនាងដែល សម្លឹងមកត្លែ។ ប្រហែលពាក្យ«គ្រែ»ធ្វើឲ្យនាងផ្ទុះទោសៈហើយ។ គេដឹងច្បាស់។ ....តែគេក៏រឹតតែចង់លោព្រោះនាងខឹង ប៉ុណ្ណឹងហើយនៅតែទប់ចិត្តបានសម្លឹងមុខគេដោយមិនតមួយម៉ាត់។ បុរសម្ចាស់បន្ទប់លើកដៃស្ពាំគងលើគែមទ្វារ

ហើយឈរសឹងថាឃ្លាត ពីនាងមិនដល់មួយចំអាមផង។
គេនិយាយតិចៗ៖
«ខ្លាចអី?»
ធីតាអភិជនរវេភ្នែកចេញទាំងដកដង្ហើមដង្ហក់ព្រោះខំទប់ចិត្តខឹង ហើយរុញបុរសនោះទៅម្ខាង ដើរហួសពីគេចូលទៅក្នុងទាំងទទឹងទទែង ចិត្ត។
«បើលោកប៉ះពាល់ខ្ញុំតែមួយសរសៃសក់ ខ្ញុំនឹងឲ្យលោកស្គាល់រសជាតិខ្នោះដៃ!»
នាងស្រដីមិនខ្លាំងតែក៏មិនស្រាល ល្មមធ្វើឲ្យយុត្តនាដែលនៅពីក្រោយខ្នងក្តាប់មាត់រុញទ្វារបិទ មួយទំហឹងលាន់គ្រាំង។
នាងភ័យ តែខំធ្វើមិនដឹងដើរបន្តទៅមុខ តែបុរសនោះស្ទុះរឹងមកពីក្រោយខ្នងប្រើដៃម្ខាងទាញដៃនាង ឲ្យបែរត្រឡប់មកវិញហើយដៃម្ខាងទៀត កន្ត្រាក់កាបូបនាងបោះចោលទៅលើតដ្ឋប្រាវ។
ពៅបញ្ញា ស្លេកមុខ តែខ្លួនប្រាណនាងក្នុងប្រអប់ដៃយុត្តនាទៅហើយ។ នាងហើបមាត់ប្រុងនិយាយតែបបូរមាត់គេឱនមកបញ្ចប់សំឡេងរបស់នាង ធ្វើឲ្យនាងប្រឹងច្រានគេចេញអស់មួយកម្លាំងកូនស្រីតែគេនៅមិន រង្គើ។ នាងគ្មានពិសោធន៍ជាមួយមនុស្សប្រុសទើបមិនដឹងថា ការនិយាយបញ្ឆោះគេមិនអាចស្តារស្ថានការណ៍បានឡើយ។ នាងត្រង់ហើយគ្មានល្បិចទីបំផុតនាងនៅតែគ្មានអីតតាំងនឹងប្រភេទ មនុស្សរបៀបនេះឡើយ តែពៅបញ្ញាឯណាទ្រាំឲ្យបុរសនេះត្រួតត្រានាងបានតាមចិត្ត។ ស្រីតូចទ័លច្រកនាងមានតែប្រើកែងជើងជាន់ប្រអប់ជើងយុត្តនាគ្រឹប ធ្វើឲ្យនរៈស្រែកវ៉ាសទាំងឈឺចាប់ហើយលែងនាងទ្រេតទ្រោតទៅក្រោយ។ ដៃគេមួយចំហៀងខ្ទប់ជើងដែលឈឺហួស ដៃមួយទៀតទាញនារីដែលខំរកច្រកគេចចេញ។ បំណាច់ឈឺថ្នាក់នេះទៅហើយ គ្មានសម្បជញ្ញៈឯណាមកឃាត់ចិត្តបុរសអ្នកលេងបានឲ្យអត់ឱនដល់នាង ទេ។ ដៃគេដែលឈោងទៅប៉ះអាវស្រីតូចបូតចេញមួយចំហៀងស្មា បង្ហាញអាវដៃតូចមួយជាន់ទៀតបង្កប់ពីក្រោមអាវធំខាងក្រៅនោះ។ សាច់ស្មានាងសខ្ចីសមនឹងតរុណីដែលមិនងាយពាក់អាវពន្លែងខ្លួន បង្ហាញសាច់នេះ ល្មមឲ្យបុរសខ្លះភ្លឹកស្មារតីបាន ប៉ុន្តែមិនដឹងហេតុអ្វីពេលយុត្តនាទាញនាងមកកៀកទៅហើយ គេនៅភ្លឹកនឹងអ្វីមួយលើស្មានោះ ហើយនៅទ្រឹងមួយខណៈមុនពេលពន្លែងដៃរុញនាងឲ្យដួលទៅលើសាឡុង។

.....ម្ចាស់បន្ទប់ជូតមាត់ទាំងកំហឹង ហើយបែរក្រោយដើរត្រឹកទៅចាក់ទឹកផឹកចោលនារីត្រកូលខ្ពស់ដែលនៅខំ ប្រវេប្រវាក្រោក។ សំឡេងនាងលាន់មកទាំងញាប់ញ័រតែបង្ហាញការឈឺចិត្តហួសហេតុ៖
«មនុស្សកំសាក! ធ្វើបាបស្រី!»
គេលើកកែវទឹកហៀបដល់មាត់ហើយ បែរជាឈប់វិញហើយសើចខឹករង្គើដល់ដើមទ្រូងនិងស្មា។យុត្តនានិយាយដោយមិនបែរមុខ៖
«ព្រោះតែខ្ញុំកំសាកហ្នឹងហើយ! ដែលនាងរួចខ្លួនថ្ងៃនេះ ពៅបញ្ញា!»
ស្រីតូចទាញអាវមកវិញត្រឹមត្រូវហើយស្ទុះក្រោកឈរត្រង់ខ្លួន។
«ទៅវិញទៅ មុនពេលខ្ញុំប្តូរចិត្ត!»
ឥតគិតច្រើន មាណវីចាកចេញតម្រង់ទ្វារចោលទាំងកាបូបចោលទាំងទ្វារចំហផ្លុងមិន ខ្វីរុញបិទឲ្យ។ នាងចុចជណ្តើរញាប់ដូចខ្មោចដេញ ហើយដៃម្ខាងជូតមាត់អើយជូតដូចបានច្រទ្បំបបូរមាត់ទៅប៉ះនឹងវត្ថុ អ្វីមួយគួរឲ្យខ្ពើមរអើមពន់ពេក។
នាងខាំមាត់ងើយមើលលេខជណ្តើរយន្តព្រោះទប់មិនឲ្យទឹកភ្នែកហូរ ចុះមក។ ក្នុងកាលៈទេសៈបែបនេះហើយនាងនៅតែព្យាយាមធ្វើមាំទាំ។
«គ្មានរឿងអីត្រូវយំ គ្មានរឿងអីឯងត្រូវខ្លាចមនុស្សបែបហ្នឹងទេពៅបញ្ញា!» ទ្វាររបើកកាលណានាងរត់សំដៅឡាន ។
ស្លាប់ហើយ....កាបូបនៅទីនោះនៅឡើយ??? បានសោពីណាមក?
នាងឱនមើលជើង....សូម្បីតែស្បែកជើងក៏របូតបាត់អស់ម្ខាងដែរ....
នាងទ្រេតខ្លួនទាំងទន់ដៃជើងទៅលើទ្វារឡាន ហើយសន្សឹមៗនាងទន់ជើងអង្គុយ។...
«លោកប៉ា! កូនអត់បានការណាស់! កូនស្អប់មនុស្សសរសៃប្រសាទនោះណាស់!»
នាងគិតម្នាក់ឯងក្នុងពេលដែលចិត្តឈឺចាប់ដូចត្រូវបាត់បង់អ្វី ម្យ៉ាងដ៏មានតម្លៃក្នុងជីវិត។ សូម្បីតែចំណេះដឹងក៏មិនសមគ្នាសូម្បីតែបន្តិចកុំថាឡើយពូជត្រកូល និងឋានៈតួនាទីសង្គម តែបុរសនោះហ៊ានមានះលើកដៃមកប្រមាថរាងកាយនាង ហើយប្រឡាក់ប្រឡូសបបូរមាត់នាង។
«ខ្ញុំនឹងប្តឹងលោកឯងឲ្យចូលគុកគ្មានថ្ងៃចេញ យុត្តនា!»
នាងនឹកដល់ឃ្លានេះក៏កាន់តែខាំលើសដើម បើពុំនោះទេ ទឹកភ្នែកប្រាកដជាស្រក់មកអ្នកផងនឹងមើលឃើញភាពទន់ខ្សោយរបស់នាង មិនខាន។ មិនដឹងជាយ៉ាងម៉េច នាងស្រាប់ប្រែទៅ

ជាបើកភ្នែកធំៗវិញ។ ប្រហែលពាក្យប្ដឹងនេះធ្វើឲ្យនាងនឹកឃើញវិញពីស្ថានភាពលោកប៉ា នាង ដែលនៅសម្រាន្តស្ងៀមលើគ្រែ។

«បើរឿងនេះឮដល់អ្នកក្រៅ....?» សំឡេងជំនួយការឈ្មោះវណ្ណៈលាន់ត្រលប់មកវិញរំលឹកក្នុងអារម្មណ៍ នាង។ នាងក៏នឹកឃើញដែរដល់សម្ដីខ្លួនអះអាងកាលនៅផ្ទះធំ «អ្នកណានិយាយមិនសំខាន់ទេ តែលោកប៉ាមិនអាចមានរឿងឡើយ!»។

តរុណីក្រោកឈរឃើតៗហើយងាកទៅរកជណ្ដើរយន្ត។ នាងដោះបង្ហើយស្បែកជើងម្ខាងដែលនៅសល់ ហើយដើរត្រលប់ទៅវិញ....

នាងងឹតឈឹងក្នុងចិត្ត.....ហើយជំនិះនាំនាងមកដល់ជាន់ទី៦វិញទាំងមិនដឹងខ្លួន....

....ទ្វារផ្ទះគេនៅតែចំហដូចពេលនាងស្ទុះចេញមក.....គេមានចេតនាមិនបិទព្រោះដឹងថានាងមុខតែវិលមកវិញ....?

....បុរសមិនសុភាពនៅអង្គុយបែរខ្នងលើសាឡុងធ្វើហាក់មិនដឹងថានាង វិលមកវិញ....គេផ្ដោតអារម្មណ៍ទៅលើអេក្រង់ទូរទស្សន៍ទុកឲ្យនាងនៅឈរ ទ្រឹងម្នាក់ឯងពីក្រោយខ្នង។

....ប៉ុន្មានវិនាទីរំលងទៅ....ទើបគេដាច់ចិត្តក្រោកដើរមកឈរពីមុខនាង ដោយទឹកមុខស្មើ។ ភ្នែកគេដែលសម្លឹងនាងគឺមិនមានអ្វីភ្ញាក់ផ្អើលឡើយ បង្ហាញថាគេដឹងពីរឿងនាងឡើងមកវិញហើយនឹងដឹងច្បាស់ថានាងចង់បានអ្វី។

ស្រីតូចដែលគ្មានស្បែកជើងកែងជាជំនួយ គឺនាងមានកម្ពស់ត្រឹមតែដើមទ្រូងគេតែប៉ុណ្ណោះ បើនាងនៅមានះមិនព្រមងើបមុខមកសម្លឹងគេ នាងប្រាកដជាមិនដឹងទេថាគេកំពុងគិតយ៉ាងណា។

ពៅបញ្ញាងើបមុខ ដែលនាងប្រាកដណាស់ថាបានទប់ទឹកភ្នែកអស់យ៉ាងល្អ តែនាងនៅតែបន្សល់ទុក្ខសោកដ៏ស្រពោនកំដរផ្ទៃមុខ ហើយថ្ពាល់ទាំងសងផុសចេញសរសៃក្រហមដោយការអៀនខ្មាសនិងភ័យ បារម្ភ។

សម្ផស្សនាងអណ្ដែតចេញនូវភាពជានារីសោភា ដែលនាងតែងតែលាក់ទុកបានពីភ្នែកអ្នកផងដោយភាពមមាញឹកនិងម៉ឺងម៉ាត់។

ពន្លឺភ្នែកនាងលែងឆ្នាស លែងឆ្មើងកន្ទ្រើង ព្រោះនាងឡើងមកវិញដោយខ្លួនឯង ព្រោះនាងត្រូវការគេ ហើយនាងជាអ្នកមកអង្វរគេ។

យុត្តនាស្រាកកំហឹងពេលឃើញអ្នកនាងធំម្នាក់ក្លាយជាឆ្មាលង់ទឹកនៅចំពោះមុខខ្លួន។ គេមិនញញឹមតែក៏មិនកំណាច។

ពៅបញ្ញានៅតែរកឃើញអ្វីមួយគួរឲ្យកក់ក្ដៅយ៉ាងអាថ៌កំបាំងក្នុង ពន្លឺភ្នែកគេដែលទាក់ទាញនាងឲ្យហ៊ាននៅឈរស្ងៀមស្ងាត់ពីមុខគេយូរ យ៉ាងនេះ។
បុរសនោះក៏មិននិយាយអ្វី....គឺគេនៅរង់ចាំមើលនាង....
....ធីតាដកភ្នែកមកវិញ...មាត់នាងដាច់ចិត្តវាចាស្រាលៗ៖
«ក្រែងលោកថា លោកដឹងពីរឿងMr Johanមែនទេ?»
នារីរង់ចាំអស់មួយខណៈ....គេនៅតែមិនស្ដី....ធ្វើឲ្យនាងមិនអាចចាំតទៅទៀតបាន ទើបងើបមុខសម្លឹងគេសាជាថ្មី។.....
....យុត្តនា នៅតែមិនដកភ្នែកចេញពីនាង។ ភាពក្រអឺតក្រទមលេចឡើងក្នុងផ្ទៃមុខនរៈយើង។ ទោះបីសរសៃភ្នែកស្រីពោរពេញដោយក្ដីអង្វរកហើយ ក៏គេមិនព្រមស្ដីតបនឹងនាងវិញដែរ។
នាងហាក់ទទួលអារម្មណ៍ថាគេស្ងៀមយូរយ៉ាងនេះ សម្លឹងមកនាងត្រង់យ៉ាងនេះ នាងមិនអាចទទួលយកពន្លឺភ្នែកគេបានយ៉ាងម៉េចមិនដឹង...មុននេះគេនិយាយ ច្រើនដូចមនុស្សស្រី....ចុះចម្លែកអីបន្ទាប់ពីមានរឿងហើយ....គេប្ដូរ ចរិតខុសស្រលះពីមុនម្លឹងៗ?



...នាងងាកមុខចេញវិញពីភាពក្រអឺតក្រទមស្ងៀមស្ងាត់របស់គេ....
«ពីណាបង្រៀនអ្ហះ? និយាយអត់មើលមុខ?»

គឺគេមិនសប្បាយចិត្តកាលដែលនាងសួរដោយមិនមើលមុខគេហ្នឹងឬយ៉ាងណា? មនុស្សហាក់លោតសោះ ចាំបាច់អីមកធ្វើប្រកែប្រកាន់ដល់ម្លឹង...កាន់តែគិត ពៅបញ្ញារឹតតែតឹងទ្រូងទ្វេ។ ប៉ុន្តែករណី Mr. Johan សំខាន់យ៉ាងនេះ នាងចាំបាច់ត្រូវលេបភាពជូរចត់នោះ ហើយងើបមុខទៅសម្លឹងគេសាជាថ្មី។

ស្នាមញញឹមលេចឡើងលើបបូរមាត់នាយ...ជាស្នាមញញឹមពេញដោយអំនួត...។ យុត្តនាមិននិយាយតែគេគិតម្នាក់ឯងក្នុងចិត្តៈ

«ទុកចោលអាឫកឆ្មើងកន្ទ្រើងរបស់នាងនៅផ្ទះធំនោះទៅមេធាវី! ពេលនេះនាងនៅផ្ទះខ្ញុំ នាងធ្វើឫកធំអត់បានទេ!»

ខ្សែភ្នែកយុត្តនាបានបញ្ចេញមកនូវភាពមានះចង់គ្រប់គ្រងនាងសូម្បី តែចរិតឫក៣។ ដែលសំខាន់គឺនាង ជាអ្នករកគេ ដូច្នេះគេចង់យ៉ាងណាគឺយ៉ាងនោះហើយ។ ពៅបញ្ញាជ្រួញចិញ្ចើមនិយាយទាំងរវេភ្នែកចុះឡើងតែនាងមិនបានងាកមុខចេញទៀតទេៈ

«លោកពិតជាដឹងថា Mr. Johanនៅឯណាមែនអត់?»

គេដឹងថានាងប្រឹងណាស់ដែលនិយាយដោយមិនងាកមុខចេញ ប៉ុន្តែភ្នែកនាងនៅតែគេចពីភ្នែកអ្នក។ គេនៅរក្សាស្នាមញញឹមហើយមិនឆ្លើយនឹងសំណួរទីពីររបស់ស្រស់ស្រី។

...ពីរបីវិនាទីរំលងទៅ...

...ការអត់ធ្មត់របស់មនុស្សគឺមានព្រំដែន ទោះបីយ៉ាងណាក៏ដោយ។

...ធីតាអភិជនដឹងថា ...បុរសនេះគ្មានចេតនាជួយលោកប៉ានាងទេ...អាចថាគេមិនបានដឹងតម្រុយ អីទាក់ទងនឹងជនបោកប្រាស់នោះផង...តាមពិតនាងមកនេះគឺមកឲ្យគេ ធ្វើបាបប៉ុណ្ណោះ។

ពៅបញ្ញាខាំមាត់បែរយឺតៗទៅរើសកាបូបនាងពីកម្រាលឥដ្ឋ ហើយចាកចេញតម្រង់ទ្វារ។... នាងខំទប់ចិត្តលែងនិយាយស្តី តែកម្លាំងចិត្តនាងបានបាត់ទៅណាអស់រលីងទៅហើយ។

«ឯងល្ងង់បំផុតពៅបញ្ញា! គេនេះហ្អីដែលព្រមជួយឯង? ក្នុងកាលៈទេសៈនេះហ្អីដែលគេមករវល់ជួយឯង? នៅមិននៅ មកឲ្យគេប្រមាថលេង!..»

ស្រីតូចដើរទៅរកទ្វារ...ដំណើរនាងមួយៗស្រាលៗសមនឹងពាក្យចាស់ថាកុល ស្ត្រីនៃត្រកូលខ្ពស់ រលាស់ជើងស្មើ ដំណើរស័ក្តិសម ធ្វើឲ្យយុត្តនាដែលតាមមើលពីក្រោយមិនអាចបន្តសកម្មភាពធ្វើបាប ចិត្តនាងបានយូរជាងនេះឡើយ។

គេនិយាយពីក្រោយខ្នងនាង៖
«មិនត្រឹមតែដឹងថា វានៅឯណាទេ! ដឹងទាំងអាអ្នកដែលនៅពីក្រោយវាទៀត!»
ស្រីស្រគត់ស្រគំបើកភ្នែកធំៗនិមិត្តតែឮសម្ដីចុងក្រោយរបស់គេ។ នាងបញ្ឈប់ជំហាន ហើយបែរក្រោយភ្លាម។ គេដើរមកយឺតៗហើយដើរហួសពីនាងទៅបិទទ្វារបន្ទប់។
....ពៅបញ្ញាលែងរវល់ពីកាយវិការនាយ....នាងលែងភ័យ...លែងខ្លាច....ក្នុង ចិត្តនាងអន្ទះសាចង់ដឹងពីមនុស្សបោកប្រាស់នោះនិងអ្នកនៅពីក្រោយ ដែលចង់ឲ្យប៉ានាងជាប់អន្ទាក់លះបង់កិត្តិយសនេះ។ នាងងាកក្រោយសួរគេដែលកំពុងដើរពីទ្វារមក៖
«អ្នកណាទៅ?»
«សុភាពបុរសក្នុងស្រោម ប៉ែន ពេជ្រប្រាថ្នា! »
ចម្លើយភ្លាមៗរបស់គេធ្វើឲ្យនាងស្លេកមុខសាជាថ្មី។ នាងសម្លឹងគេយ៉ាងមុតហាក់ចង់មើលឲ្យធ្លុះថា ពាក្យដែលគេនិយាយនេះពិតឬប្រឌិត។ នរៈលើកចិញ្ចើមដាក់នាង ហាក់ចង់មានន័យថា «ឮហើយពេញចិត្តឬនៅ?»
តែមាត់នាងខំបដិសេធញាប់ស្មេរ៖
«អត់ទេ!.....មនុស្សកុហក!»
ថាហើយស្រីតូចបែរខ្នងគេចចេញពីកែវភ្នែកយុត្តនា បណ្ដោយឲ្យនរៈម្ចាស់ផ្ទះឈានមកក្រសោបចង្កេះនាងពីក្រោយហើយក៏នាង លែងគេចចេញដែរព្រោះវិញ្ញាណនាងកំពុងហោះហើរចោលរាងកាយទៅរកសុបិន ដ៏អាក្រក់មួយ។
«មិញប៉ានាងខឹងពេកប្រញាប់តែបោកទូរសព្ទចោលកុំអីខ្ញុំបង្ហើប ប្រាប់គាត់ហើយ ថាកូនប្រុសធំ របស់គាត់ជាអ្នកលេងគាត់!» គេនិយាយធ្វើហីក្នុងពេលដែលក្លិនប្រហើរពីសក់ស្រីអ្នកច្បាប់កំពុង ដុតរោលអារម្មណ៍។ គេមិនដឹងទេថាវាចាចុងក្រោយនេះ បានធ្វើឲ្យពៅបញ្ញាវិលវល់ដូចទូកអណ្ដែតរកត្រើយមិនឃើញ។
សំឡេងនាងលាន់មកភ្លាមៗតែញ័រទទ្រើក៖
«ប៉ាខ្ញុំមិនជឿទេ! ហើយខ្ញុំក៏អត់ជឿដែរ!.»
យុត្តនាដឹងហើយថាហេតុអ្វីនាងរំជួលចិត្តដល់ម្លឹង។
កាលដែលបុរសចំណាស់ម្នាក់ដឹងថា កូនប្រុសខ្លួននៅពីក្រោយអំពើបំផ្លាញខ្លួនគាត់ គាត់មុខជាមិន អាចទ្រាំទ្របានឡើយ។ ចំណែក ពៅបញ្ញា នាងរំជួលចិត្តយ៉ាងនេះ ក៏ដោយសារតែនាងមិនចង់ឲ្យឪពុកនាងរន្ធត់ចិត្តនឹងការពិតនេះដែរ។

«អញ្ជឹងចាំភ័យធ្វើអី?»
ស្រីស្អាតលែងទប់ចិត្តនាងដំឡើងសំឡេងស្រែកៈ
«អត់ទេ! ឈប់លេងល្បិចស្មោកគ្រោកអញ្ជឹងទៅយុត្តនា!»
យុត្តនាខឹងនាងឬមួយគេភ្ញាក់នាងព្រោះនាងវាចាខុសចិត្តទេដឹង បានជាគេបំបែរនាងមកចំមុខហើយម្រាមដៃម្ខាងអង្អែលថ្ពាល់ខាងឆ្វេង របស់នាង។
«ស្មានថាគេចពីការពិតហ្នឹង ដោះស្រាយអីបាន? បានទេតើ ចាំខ្ញុំសាកមើល តើពេលប៉ាដឹងហើយគាត់ជឿដែរឬអត់? ភ្នាល់គ្នាទៅ ក៏ល្អលេងដែរ!»
ធីតាត្រកូលហង្សរលាស់ដៃនាយចេញ ហើយនិយាយតបវិញទាំងភ្នែកក្រហមដោយវិបត្តិៈ
«ប៉ាខ្ញុំមិនដែលធ្វើស្អីលោកទេយុត្តនា! នៅមិននៅ លោកមកចងអាឃាតគាត់ធ្វើអី? លោកអត់ការងារធ្វើណាស់ម៉េចមិនទៅធ្វើអីមានប្រយោជន៍ជាងនេះទៅ មករករឿងគាត់ធ្វើអី?»
មិនដឹងយ៉ាងម៉េចឲ្យតែនាងចេញអាកប្បកិរិយាច្រឡោតដាក់នាយ នាយកើតចិត្តមានះចង់ឌឺដងនាងមួយរំពេច។ បុរសលែងដៃពីកាយនាង ហើយនិយាយដោយមុខស្មើៈ
«ខ្ញុំអត់បានធ្វើអីគាត់ទេ ពៅបញ្ញា! គាត់ជាឧកញ៉ា គាត់ជាអ្នកធំ ខ្ញុំហ៊ានធ្វើអីគាត់ទៅ? ពេលនេះកូនប្រុសគាត់ខ្លួនឯងជាអ្នកលេងគាត់ ខ្ញុំគ្រាន់តែជាអ្នកក្រៅ ដឹងរឿង ចិត្តល្អចង់ប្រាប់គាត់តើ!»
ស្រីក្រមុំអភិជនដឹងថា នាងតក់ក្រហល់ពេកទៅជាស្រែកដាក់បុរសនេះទទឹងទិសបានជាគេខឹង និយាយចាក់បណ្ដោយ នាងប្រញាប់សម្រួលទឹកមុខនិយាយតបៈ
«យុត្តនា! ខ្ញុំសុំចិត្ត! លោកកុំផ្សព្វផ្សាយរឿងនេះ!»
គេអស់ពីស្រពន់ចិត្ត ទៅជាក្របួចមាត់ញញឹមស្មើៗ។ គេខំទប់មនោសញ្ចេតនាទន់ភ្លន់តែមិនអាចលាក់កំបាំងក្រសែភ្នែកដែល សម្លឹងនាងដោយស្រទន់នោះទេៈ
«បើខ្ញុំព្រម នាងយកអីមកសងខ្ញុំពៅបញ្ញា?»
នាងរវេភ្នែកព្រោះភ្ញាក់ខ្លួន។
ត្រូវហើយតើនាងមានអីទៀត? ទ្រព្យសម្បត្តិ កិត្តិយស ឪពុកក៏សម្រាន្តលើគ្រែ បងប្រុសខុសម្ដាយកំពុងតែសប្បាយក្នុងការរុញគ្រួសារនាងទម្លាក់ ទឹក។
នាងរវេភ្នែករិះគិតនៅចន្លោះភាពទាល់ច្រកនិងអស់សង្ឃឹម ទាំងនិយាយអ្វីមិនចេញ ឆ្លើយមិនរួចចំពោះសំណួររបស់យុត្តនាឡើយ។
បុរសម្ចាស់ផ្ទះដើរចេញពីនាងទៅក្បែរសាឡុង។ នាងតាមដានកាយវិការគេជាប់ ព្រោះបារម្ភ

តែម្យ៉ាងគឺគេនិយាយរឿងអស់នេះប្រាប់អ្នកទីបី។
យុត្តនាលូកទៅរកកុំព្យូទ័រយួរដៃនៅលើកូនតុកាហ្វេនោះហើយចុចបើកឯកសារអ្វីម្យ៉ាង។
«ឯងបោកប្រាស់ឧកញ៉ា ប៉ែន ពេជ្រ យកលុយច្រើនយ៉ាងនេះទៅណា?» សំឡេងក្នុងវីដេអូទាញចិត្តស្រីតូចឲ្យឈានទៅកាន់ទីនោះដោយមិនដឹង ខ្លួន។ នោះគឺរូបភាពជនបរទេសម្នាក់ដែលនាងដឹងថាប្រាកដជា ចូហាន់ ( Johan) នោះហើយ។ វីដេអូមិនបានបញ្ចេញរូបអ្នកសួរចម្លើយទេ តែជនបរទេសនោះអង្គុយលើកៅអីមួយទំនងជាត្រូវបានគេចាប់បង្ខំឲ្យ ឆ្លើយទោះបីដៃគ្មានជាប់ចំណងក៏ដោយ។
«ខ្ញុំអត់បានលុយ១១លាននោះទេ! ខ្ញុំធ្វើតាមគេប្រាប់ គេឲ្យខ្ញុំតែមួយលានប៉ុណ្ណោះ!»
«ឯងល្ងង់ម្ល៉េះ! លុយ១១លាន គេឲ្យឯងមួយលាន គេយក១០លាន?»
«ខ្ញុំគ្មានផ្លូវជ្រើសរើស! ខ្ញុំចាញ់ល្បែងជំពាក់លុយច្រើនពេក!»
ពៅបញ្ញាសឹងថាងងឹតមុខដួលតែនាងផ្ទៀងស្តាប់អ្នកសួរចម្លើយ បន្តសំណួររបស់គេ៖
«អញ្ចឹងប្រាប់ម៉ោ! អ្នកណាបញ្ជាឯង!»
«កូនប្រុសគាត់! ប៉ែន ពេជ្រប្រាថ្នា!»
«ឯងស្មានថាយើងជឿឯង? ចង់ឈឺសាច់ទៀតអ្ហេស៎ បាននិយាយកុហក!»
«ជាការពិតណាស់! ឧកញ៉ា ប៉ែន ពេជ្រ មានប្រពន្ធក្រោយចោលប្រពន្ធមុននិងកូនបីនាក់! ផ្ទះនោះ ទុកគាត់ជាសត្រូវ គេចង់ឲ្យគាត់រលាយហើយចង់ឲ្យកូនស្រីប្រពន្ធចុងគាត់ទាល់ច្រក»។
នារីអ្នកច្បាប់ញាប់ញ័រក្នុងចិត្ត នាងទន់ជង្គង់រកកល់ឈរលែងជាប់ម្តងៗទៅហើយ។ យុត្តនាចុចបិទកុំព្យូទ័រហើយដើរមកប្រឈមនឹងនាង។
«ដឹងអស់ហើយសប្បាយចិត្តឬនៅ? ត្រូវការបញ្ជូនអាបារាំងនេះទៅចូលទ្រុងថ្ងៃណា?»
នាងដឹងហើយថា Mr. Johan កំពុងស្ថិតក្នុងកណ្តាប់ដៃនាយ។ មេធាវីភ័យស្លេកនៅពេលដែលឮប្រយោគនេះនាងបដិសេធញ៉ាញ៖
«កុំ! កុំឲ្យប៉ូលិសឃើញគេ!»
យុត្តនាសើចញឹមៗព្រោះគេដឹងថានាងមុខតែនិយាយអញ្ចឹង។ គេគិតម្នាក់ឯងក្នុងចិត្ត៖
«ខ្លាចគេបើកកកាយរឿងបងប្រុសនាង? ខ្លាចបងប្រុសក្រៅខោហ្នឹងវាជាប់គុក? ខ្លាចប៉ានាងដឹងហើយទ្រាំនឹងរោគបេះដូងមិនបាន?»
សំណួរគេត្រូវទាំងអស់ ត្រូវដល់ថ្នាក់នាងនិយាយតបមិនចេញគឺគិតពីសម្លឹងគេធ្មឹងបន្លប់ពេលវេលាដ៏ទាល់ច្រកនេះ។ គេខ្សឹបតិចៗទាំងសម្លឹងមុខនាងជាប់៖

«ស្រីល្ងង់! អូ ច្រឡំ! គឺអ្នកនាងធំទេ! អ្នកនាងធំល្ងង់ម៉េះ? បើនាងមិនចាប់នាយ Johan ដាក់គុក ប៉ានាងឆ្លើយតបនឹងភាគហ៊ុនអស់ហ្នឹងរបៀបម៉េច ?»
នាងដឹងហើយថាមកទីនេះទ្រាំសព្វទ្រាំគ្រប់ព្រោះតែតាមរកជនបរទេស នោះចាប់ទៅទទួលទោសដើម្បីលាងជម្រះបញ្ហាឪពុកតែពេលនេះរឿងជាន់លើ រឿង អ្នកនៅក្រោយគឺកូនប្រុសប្រពន្ធដើមរបស់ប៉ានាង បើជនបរទេសនោះត្រូវប៉ូលិសចាប់គេមុខតែសារភាពប៉ានាងរួចខ្លួនមែនតែគ្រួសារទាំងមូលត្រូវហែកហួរ ខូចឈ្មោះ ចំណែកសុខភាពប៉ានាងតើទទួលយកវិបត្តិនេះកើតដែរទេ។
យុត្តនាសម្លឹងទៅស្រីតូចដែលឈ្ងោកមុខ...ព្រោះតែគ្មានមធ្យោបាយ។ គេដឹងថា បញ្ហានេះធំហួសពីសមត្ថភាពដែលស្ត្រីទៀងត្រង់ដូចនាងអាចដោះស្រាយ ចេញ។ គេមិននិយាយអ្វីក៏បែរដើរទៅស្រូបយកខ្យល់អាកាសនៅវានហាល ខាងមុខវិញធ្វើហី។ មិនដឹងថាតាមពិតទៅគេចង់គេចពីភាពទុក្ខសោករបស់នាង ឬមួយគេមានចេតនាឲ្យនាងចេញទៅកាន់ទីនោះតាមពីក្រោយគេឬយ៉ាងណា ទេ....ព្រោះថាក្រោយពីគេដើរចេញទៅបន្តិច....នាងដើរយឺតៗទៅតាមពី ក្រោយមែន....

....ក្លិនក្រអូបរបស់នាងហើរដែលរសាត់មកតាមវាតា បញ្ជាក់ប្រាប់ថានាងនៅមិនឆ្ងាយពីនាយឡើយម៉្លោះហើយមិនបាច់ងាក ក្រោយទេ នាយនិយាយខ្លីទៅកាន់នាង៖
«ក្រៅពីនាង គ្មានអ្នកណាដឹងរឿងហ្នឹងនៅឡើយទេ ពៅបញ្ញា!»
ស្រីតូចត្រេកអរឡើងវិញដូចបានអ្វីមួយមកបន្តជីវិត។ នាងឈានចូលទៅកាន់តែកៀកល្មមពេលនាយងាកមកដែរ។ ពន្លឺត្រេកអរផុសចេញពីកែវភ្នែកនាង...មិនមែននាយមើលមិនដឹងទេ អញ្ចឹងហើយបានជាយុត្តនាបានចិត្តលូកដៃមកកៀកចង្កេះធីតាហើយ បំបែរនាងទៅរកលំហអាកាស។
«ធ្វើកុំភ័យមើល៍! ទេសភាពនៅទីនេះគ្រាន់បើដែរតើ! ថ្ងៃក្រោយឧស្សាហ៍មកលេងផង!»
ស្រីតូចនៅទីទើរ នាងចង់បម្រះចេញពីក្នុងរង្វង់ដៃគេតែអ្វីមួយបង្ខំឲ្យនាងសំងំ ស្ងៀមវិញ។....គឺនាងខ្លាចចិត្តគេប្រាកដណាស់។
«យើងមានរឿងក្នុងដៃគេច្រើនដល់ម្លឹង! ឲ្យតែគេខឹងបន្តិច យើងនឹងយ៉ាប់ហើយ!» នាងគិតម្នាក់ឯងទាំងក្តុកក្តួលចិត្ត។ ទោះយ៉ាងណានាងនៅតែមានអារម្មណ៍ថាប្រុសម្នាក់នេះមិនបំពាននាងឲ្យ លើសពីនេះឡើយ....!

អ្វីទៅដែលធ្វើឲ្យនាងមានជំនឿចិត្តម្ល៉េះ?...
គ្មានចម្លើយច្បាស់លាស់ទេ! អារម្មណ៍គឺអរូប តែវាជាអារម្មណ៍សម្រាប់មនុស្សពីរនាក់ដែលដឹងគ្នាទៅវិញទៅមកដោយញាណពិសេស។
សំណើចគេស្រាលលាន់មកកាត់ផ្ដាច់ការរិះគិតរបស់នាង។ ពៅបញ្ញាចេញចំហាយក្ដៅៗតាមថ្ពាល់ទាំងសងនាងយល់ថាគេកំពុងតែ ចំអកដែលនាងក្លាយជាកូនចៀមក្នុងរង្វង់ដៃគេ ប៉ុន្តែតាមពិតនាងគិតខុសគឺយុត្តនាសើចចំអកឲ្យបុរសម្នាក់ទៀតដែល កំពុងជិះឡានចុះឡើងៗនៅលើផ្លូវ។
ពេលនាងងាកមើលមុខគេថាហេតុអ្វីគេនៅសុខៗក៏សើច ។
យុត្តនាបួញមាត់ជាសញ្ញាឲ្យនាងសម្លឹងទៅក្រោម។ ទោះជាន់ទី៦ឆ្ងាយបន្តិចតែពៅបញ្ញាទំនងជាចំណាំរថយន្តនោះបាន។ នាងដឹងថា នោះជារថយន្តរបស់វិទ្ធិជំនួយការដ៏ម៉ត់ចត់របស់ប៉ានាង។
«មានគេឈឺឆ្អាលដល់ហើយហ្ន៎! ថៅហ្វាយស្រីចេញមកមិនទាន់បានប៉ុន្មានកូនថៅជិះកាត់ផ្លូវនេះចង់ រេចអស់ទៅហើយ!»
ពៅបញ្ញាហួសចិត្តដែលសូម្បីតែរថយន្តរបស់ជំនួយការនាងក៏យុត្តនា ស្គាល់ដែរមិនដឹងថាគួរហៅគេថាជាអ្នកស៊ើបការណ៍ពិសេសឬជនអន្ធពាល ខាងចាប់ជំរិតទេ។
«ខ្ញុំត្រូវទៅវិញហើយ! លោករក្សាពាក្យសន្យាផង!»
នាងប្រលេះដៃគេចេញពីចង្កេះ តែគេមិនលែងហើយឈ្ងោកមកថើបនាងពីក្រោយគល់ក។
«សន្យាអីទៅ?»គេខ្សឹបធ្វើពើ។
ធីតារើបម្រះទាំងភ័យបារម្ភខ្លាចមានគេមើលមកឃើញផង និងភិតភ័យព្រោះនាងមិនដែលស្គាល់បុរសណាពីមុនមកផង។
«លោកសន្យាមិននិយាយរឿងបង ប្រាថ្នា នៅពីក្រោយកលល្បិច១១លានដុល្លារនោះឲ្យអ្នកទីបីដឹង!»
គេមិនឆ្លើយតែកម្លាំងដៃគេធ្វើឲ្យនាងដឹងថាគេមិនលែងនាងដោយងាយឡើយ។ នាងមានតែវិធីមួយគត់គឺអង្វរគេម្ដងទៀត។
«យុត្តនា! ខ្ញុំមិនមែនជាស្រីស្អាតទេ! លោកកុំចាំបាច់ធ្វើអញ្ចឹង»
យុត្តនាសើចខឹកសាជាថ្មី។ គេហាក់មានបំណងសើចចំអកឲ្យមធ្យោបាយដ៏អន់នេះ។ គេនិយាយឱដងះ

«មុននឹងមក អត់ត្រៀមខ្លួនទេ!? វាមិនដែលមានប្រុសណាហៅស្រីមកជួបកណ្ដាលយប់ ហើយមិនធ្វើអីនោះទេ ពៅបញ្ញា!»
គេនិយាយត្រង់ៗហួស អសុរោះហួសរហូតដល់ថ្នាក់ស្រីតូចអាម៉ាស់ស្ទើរមុជដីគេចឲ្យបាត់ពីភ្នែកគេ។ នាងត្រឹមត្រូវហួស ស្លូតហួស និងបុរាណហួសដល់ថ្នាក់គ្មានពាក្យតបនឹងបុរសនេះទៀតឡើយ។
ទោះជាយ៉ាងណាក៏គេលែងដៃពីនាងសន្សឹមៗ។
«ខ្ញុំឲ្យនាងជំពាក់! ថ្ងៃក្រោយត្រៀមខ្លួនឲ្យស្រួលផង!»
គេនិយាយខ្ពី តែធ្វើឲ្យនាងព្រឺសម្បុរដូចមើលកុនខ្មោច។ នារីនិយាយដោយមិនមើលមុខ៖
«លោកស្អប់ខ្ញុំណាស់! ធ្វើអញ្ចឹងធ្វើអី?!»
យុត្តនាច្រត់ដៃទាំងទ្វេលើបង្កាន់ដៃសើចក្អាកក្អាយម្នាក់ឯង។ សើចអស់ចិត្តគេបែរមកប្រឈមនឹងនាងសាជាថ្មី។ គេសម្លឹងនាងដោយមិនចេញស្ដី ធ្វើឲ្យស្រីអ្នកច្បាប់ទៅជាតឹងទ្រូង។ នាងកំពុងពិបាកថាប្រាក់១១លានត្រូវដោះស្រាយយ៉ាងណាព្រោះថាបើ បង្ហាញមុខបរទេសបោកប្រាស់នោះ ក៏មិនបានខ្លាចគេបកអាក្រាតរឿងបងប្រុសនាងនៅពីក្រោយរឿងហេតុនេះហើយលោកប៉ានាងឈឺចិត្តរឹតតែខ្លាំង។ ពេលនេះមកជួបមនុស្សមានរោគចិត្តទៀត នាងណែនទ្រូងស្ទើរប្រេះ។
« ស្អប់ឬស្រលាញ់មិនសំខាន់ទេ ពៅបញ្ញា!»
ជាមេធាវី បើថាមិនបានសម្ដីគឺមិនពិតឡើយ។ ប៉ុន្តែចំពោះមុខបុរសនេះ នាងរកអ្វីឆ្លើយមិនបានសោះ។ នាងដឹងថានាងចាញ់ប្រៀបគេជានិច្ច....តតាំងក៏គ្មានប្រយោជន៍...នៅបន្តក៏ គ្មានន័យស្រីបង្វែរកាយដើរមួយៗតម្រង់ទៅមាត់ទ្វារទាំងលែងមាត់ លែងក។
https://www.facebook.com/306238139571077/videos/1117606281729094